ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Feb-2012, 09:21
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី២៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ដេល លីសាក់
*(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

លោក វ៉ែន ពៅ

លោកស្រី ម៉ុច សុវណ្ណារី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ស៊ីន សុវ៉ន | ខ្មែរ |
| លោក បាណាបេ ណេគ្វី | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក នួន ជា | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**

សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្ដើមពី ........................................................ ទំព័រ ០៥

សួរដោយលោក បាណាបេ ណោគ្វី ផ្ដើមពី........................................................ទំព័រ ១៦

សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្ដើមពី ........................................................ ទំព័រ ៣១

សួរដោយលោក ម៉ៃខល ផេសមិន ផ្ដើមពី........................................................ទំព័រ ៣៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ តាមកាលវិភាគសវនាការដែលបានគ្រោងទុក អង្គជំនុំជម្រះបន្តការស្តាប់ចម្លើយជនជាប់ចោទ នួន ជា ដែលនឹងសួរដោយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ តែមុននឹងឈានចូលដល់ការផ្តល់វេទិកាទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីឲ្យបានជ្រាបថា ចាប់ពីថ្ងៃស្អែកទៅគឺតាមកាលវិភាគដែលបានជម្រាបជូនរួចហើយ គឺអង្គជំនុំជម្រះមានបំណងស្តាប់សក្ខីកម្មសាក្សីលោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា។

ហើយតាមការស្នើសុំរបស់ភាគីក្នុងការសួរដេញដោលចំពោះសាក្សីរូបនោះ គឺខាងសហព្រះរាជអាជ្ញាបានស្នើសុំមួយថ្ងៃ ហើយនិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងក្នុងការសួរប្រហែលជា៣០នាទី។ ដូច្នេះអង្គជំនុំជម្រះសម្រេចផ្តល់វេទិកាមួយថ្ងៃឲ្យទៅសហព្រះរាជអាជ្ញាហើយនិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:០៤:០៩]

ទីពីរគឺភាគីខាងមេធាវីការពារក្តី មេធាវី នួន ជា សុំរយៈពេលមួយថ្ងៃ មេធាវី អៀង សារី សុំរយៈពេលមួយថ្ងៃ ហើយមេធាវី ខៀវ សំផន សុំរយៈពេលបួនម៉ោង។ អង្គជំនុំជម្រះសម្រេចផ្តល់ចិរវេលាពីរថ្ងៃសម្រាប់ក្រុមមេធាវីការពារក្តីទាំងបីក្រុម ដូច្នេះសូមភាគីជ្រាបជាព័ត៌មាន។ ហើយអង្គជំនុំជម្រះមិនចំណាយពេលវេលាក្នុងការសួរសាក្សីរូបនេះទេ សួរតែសំណួរបឋមប៉ុណ្ណោះ អង្គជំនុំជម្រះនឹងប្រគល់ភារៈទៅសួរដំបូងគេដោយ ទៅឲ្យសហព្រះរាជអាជ្ញាក្នុងការសួរ-- ស្តាប់សក្ខីកម្មចំពោះសាក្សី ឆាំង យុ ដែលជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា។

សូម-- ជាបន្តអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា មកកាន់ឈើរាងវង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះ!

*(ជនជាប់ចោទ នួន ជា ទៅកាន់ឈើរាងវង់ក្រចកសេះ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ អម្បាញ់មិញ ដោយបានស្ដាប់អ្វីដែលលោកប្រធានបានជម្រាបជូនអង្គសវនាការអម្បាញ់មិញ យើងខ្ញុំហាក់ដូចជាមានភាពអត់ច្បាស់លាស់បន្ដិច។ អម្បាញ់មិញលោកប្រធានបានមានប្រសាសន៍ថា មេធាវីមេធាវីនាំមុខមានបំណងសួរទៅលើលោក ឆាំង យុ ក្នុងរយៈពេលសាមសិបនាទី ហើយលោកប្រធានក៏បានបញ្ជាក់ថាផ្ដល់រយៈពេលកន្លះថ្ងៃសម្រាប់ព្រះរាជអាជ្ញា ហើយនិងខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ អ៊ីចឹងសូមលោកប្រធានមេត្តាបញ្ជាក់បន្ដិច ថាតើរយៈពេលប៉ុន្មានដែលលោកប្រធានផ្ដល់ទៅដល់ខាងព្រះរាជអាជ្ញា ហើយរយៈពេលប៉ុន្មានដែលអង្គជំនុំជម្រះផ្ដល់ជូនមេធាវីនាំមុន។ សូមអរគុណ។

[០៩:០៦:១២]

**ប្រធានអង្គជំនុំ៖**

ដោយអំមិញគឺ-- អរគុណដែលចង់បញ្ជាក់បញ្ហានេះឲ្យច្បាស់ គឺអង្គជំនុំជម្រះផ្ដល់វេទិកាមួយថ្ងៃសម្រាប់សហព្រះរាជអាជ្ញា និងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំកន្លះម៉ោង ដូច្នេះកន្លះម៉ោងហ្នឹងអង្គជំនុំជម្រះផ្ដល់វេទិកាកន្លះម៉ោងបន្ទាប់ពីសហព្រះរាជអាជ្ញាបានសួរ។ ដូច្នេះក្នុងមួយថ្ងៃហ្នឹង គឺសហព្រះរាជអាជ្ញាសួរ តែលៃទុកពេលកន្លះម៉ោងចុងក្រោយសម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

ច្បាស់ទេ?

**លោក ពេជ អង្គ៖**

បាទ លោកប្រធាន តាមខ្ញុំចាំ ខ្ញុំធ្លាប់ស្នើសុំរយៈពេលពីរម៉ោងសម្រាប់សួរទៅលើលោក ឆាំង យុ មិនដែលសុំកន្លះម៉ោងទេ លោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៨:៣៤]

**ប្រធានអង្គជំនុំ៖**

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តើលោកមានសំណើច្បាស់លាស់ទេ កន្លង

មក? តាមតែព័ត៌មានដែលអង្គជំនុំជម្រះបានទទួល គឺសំណើសុំរបស់ភាគីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញភាពមិនច្បាស់លាស់អំពីពេលវេលាទេ គ្រាន់តែខ្លួនថាមិនមានសំណួរអ្វីច្រើនទេ ដែលត្រូវសួរទៅសាក្សីរូបនេះ។ អ៊ីចឹងហើយពេលវេលាដោយសារមិនមានសំណួរច្រើននេះអាចទំនងកន្លះម៉ោងវាជាការសមរម្យ។ ដូច្នេះបញ្ហាដែលលោកលើកឡើង គឺថាសុំឲ្យ-- បើលើកក្រោយលោកឲ្យដាក់បញ្ជាក់ពេលវេលាហ្នឹងឲ្យបានច្បាស់លាស់ ចៀសវាង ប្រសើរៗជាជាងក្នុងការដែលប្រើប្រាស់ត្រឹមតែទំនងជាមិនមានសំណួរអ្វីច្រើនក្នុងការសួរសាក្សីរូបនេះទេ។

ទីពីរឥឡូវនេះ ថាតើលោកត្រូវការពេលវេលាប៉ុន្មាននៅក្នុងការសួរសាក្សីដែលយើងបានកំណត់នឹងធ្វើចាប់ពីថ្ងៃស្អែកទៅនេះ? ដើម្បីអង្គជំនុំជម្រះលៃលកក្នុងរយៈពេលសមស្រប។

[០៩:០៩:៥១]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រម យើងខ្ញុំបានស្នើសុំនៅពេលសវនាការនេះតែម្តង ជាមួយ-- នៅពេលដែលភាគីដទៃទៀតបានជម្រាបអង្គជំនុំជម្រះអំពីពេលវេលារបស់ខ្លួន យើងខ្ញុំបានស្នើសុំរយៈពេលពីរម៉ោង។ ពេលនេះក៏យើងខ្ញុំក៏នៅតែរក្សាសំណើសុំរយៈពេលពីរម៉ោងនេះដដែល។ សូម--

**ប្រធានអង្គជំនុំ៖**

ចុះខាងសហព្រះរាជអាជ្ញាវិញយ៉ាងម៉េចដែរ? អាចកាត់បន្ថយពេលវេលាខ្លះ ដើម្បីឲ្យប្រគល់ទៅខាងសហមេធាវីនាំមុខ ដើមបណ្តឹងរដ្ឋប្បវេណីបានទេ? ក្នុងរយៈពេលមួយថ្ងៃដែលយើងធ្វើការសម្រេចអម្បាញ់មិញនេះ ដើម្បីឲ្យលោកសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខធ្វើការបែងចែកពេលវេលាសម្រាប់សួរសាក្សី ដែលយើងបានកំណត់គោលដៅក្នុងការតាំងសំណួរសួរដេញដោលនៅចាប់ពីថ្ងៃស្អែកទៅនេះ។

**លោក ឌេល លីសាក់៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម គឺថាខ្ញុំនឹងត្រូវពិនិត្យជាមួយអ្នកច្បាប់ដែលត្រូវពិភាក្សា ហើយយើងនឹងពិនិត្យមើលថាតើលទ្ធភាពប៉ុនណាដែលយើងត្រូវការ? ហើយបើសិនជាមានភាពចាំបាច់ ប្រហែលជាខ្ញុំត្រូវការពេលមួយថ្ងៃកន្លះ ឬក៏លើសពីនោះបន្តិច។ ហើយខ្ញុំត្រូវពិនិត្យជាមួយក្រុមការងារ និងឆ្លើយតបទៅវិញក្នុងរយៈពេលឆាប់ៗ។

[០៩:១១:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសួររួចហើយ ហើយខាងសហព្រះរាជអាជ្ញាស្នើសុំមួយថ្ងៃអម្បាញ់មិញនេះ គឺបានសួរ បានសុំរួចហើយ មិនមែនមកទើបសុំពេលនេះទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំប្រហែលជាកំហុសការបកប្រែទេលោកប្រធាន។ ខ្ញុំនិយាយថា យើងបានស្នើសុំមួយថ្ងៃ មិនមែនថាស្នើសុំមួយថ្ងៃកន្លះនោះទេ យើងខ្ញុំស្នើសុំមួយថ្ងៃដើម្បីសហព្រះរាជអាជ្ញាសរុប។ ហើយខ្ញុំនឹងពិនិត្យជាមួយអ្នកច្បាប់របស់ខ្ញុំ ដើម្បីពិនិត្យមើលថាតើត្រូវការពេលប៉ុណ្ណឹងគ្រប់ ឬមិនគ្រប់ ហើយនិងឆ្លើយប្រាប់តុលាការវិញ បន្ទាប់ពីព្រឹកនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៣:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរ សួរដេញដោលចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ មេធាវីនាំមុខសូមអនុញ្ញាតលោកប្រធាន និងលោក លោកស្រីចៅក្រម ប្រគល់សិទ្ធិនៅក្នុងការសួរសំណួរទៅលើលោក នួន ជា ជូនទៅលោកស្រី ស៊ីន ស៊ីវ៉ន លោកស្រីមេធាវី ស៊ីន ស៊ីវ៉ន និងលោកមេធាវី បាណាបេ ណេគ្វី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ ហើយអង្គជំនុំជម្រះក៏សូមរំឭកសាជាថ្មីម្តងទៀតចំពោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិថា នៅក្នុងកិច្ចពិភាក្សាដេញដោលចំពោះជនជាប់ចោទនៅក្នុង នៅពេលនេះគឺធ្វើក្នុងក្របខ័ណ្ឌបរិបទនៃអង្គហេតុទាំងឡាយដែលពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ។ ហើយសូមចងចាំបញ្ហានេះឲ្យច្បាស់។ សូមអញ្ជើញ សូមប្រគល់វេទិកា។

[០៩:១៤:៣៣]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ័ន៖**

ចាស! សូមអរគុណ។ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមដែលជាក្រុមប្រឹក្សា សូមគោរពអង្គជំនុំជម្រះទាំងមូល។

**ស៖** សូមជម្រាបសួរលោក នួន ជា។ ខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។ នាងខ្ញុំសូមសួរសំណួរលោកពីរបីសំណួរ។ ដោយថ្ងៃនេះ ជាថ្ងៃសវនាការមួយដ៏សំខាន់ ហើយក៏ជាឱកាសមួយដ៏សំខាន់សម្រាប់លោក ដើម្បីស្វែងរកការពិត។ ហើយការពិតយុត្តិធម៌នោះគឺថាមិនមានតែលោកទេ គឺសម្រាប់ដើមបណ្ដឹងដែលជាជនរងគ្រោះផង។ ហេតុនេះសូមឲ្យលោកហ្នឹងមេត្តាសហការជាមួយយើងដើម្បីស្វែងរកការពិតហ្នឹង។ នាងខ្ញុំសូមសួរសំណួរទៅលោកបួនប្រាំសំណួរ។

**ស៖** សំណួរទីមួយនាងខ្ញុំសូមជម្រាបសួរលោកថា នៅឆ្នាំ១៩៤៤ លោកបានសិក្សាផ្នែកច្បាប់នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ (ស៊ីក) នៅទីក្រុងបាងកក ប្រទេសថៃមែនទេលោក?

**លោក នួន ជា៖**

**ឆ៖** សូមជម្រាបគោរពលោកប្រធាន គោរពបងប្អូនរួមជាតិទាំងអស់ក្នុងទីនេះ និងទូទាំងប្រទេស។ មែន!

**ស៖** ចាស អរគុណ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកថា ពេលដែលលោកទៅរៀននៅប្រទេសថៃហ្នឹង លោកបានដាក់ឈ្មោះថា រុងឡឺត ឡៅឌី មែនទេ? ពេលនុ៎ងលោកប្ដូរឈ្មោះ។

**ឆ៖** ពេលនោះព្រះរាជបញ្ញត្តិថៃ គេឲ្យខ្មែរគេមកគ្រប់គ្រងដូចនៅបាត់ដំបង សៀមរាប ឲ្យប្រែឈ្មោះជាថៃទាំងអស់។ ដូច្នោះខ្ញុំដាក់ឈ្មោះ រុងឡឺត ឡៅឌី។

**ស៖** ចាស អរគុណ។ គ្រាន់តែខ្ញុំចង់ឲ្យលោកឆ្លើយថា មែន ឬក៏មិនមែន។ ចុះឈ្មោះនុ៎ងអ្នកណាជាអ្នកដាក់ជូនលោក?

**ឆ៖** លោកសង្ឃ។

[០៩:១៦:២៦]

**ស៖** លោកសង្ឃ។ អរគុណ។ ហើយសំណួរទីពីរ នាងខ្ញុំចង់ជម្រាបសួរលោកដែរថា ក្រោយពេលដែលលោកបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យធម្មសាស្ត្រ លោកបានចូលរួមជាមួយចលនាតស៊ូ

ដើម្បីទាមទារឯករាជ្យមែនទេ?

**ឆ៖** ជម្រាបលោកប្រធាន គោរពលោកប្រធាន ខ្ញុំមិនទាន់ចប់ការសិក្សានៅធម្មសាត្រទេ ទើបនឹងរៀនឆ្នាំទីមួយ ប៉ុន្តែដល់ខ្ញុំឃើញថា រៀនហ្នឹងវាឥតប្រយោជន៍ ទៅបម្រើអ្នកណា បម្រើតែវណ្ណៈកាន់អំណាចហ្នឹង ហើយប្រទេសជាតិយើងកំពុងមានការតស៊ូដើម្បីរំដោះជាតិ ដូច្នោះខ្ញុំសូមឈប់ ខ្ញុំចេញមកតស៊ូ។

**ស៖** ចាស សូមអរគុណ។ ចុះពេលដែលលោកតស៊ូជាមួយបក្សកុម្មុយនីស្តថៃ ក្នុងគោលបំណងដើម្បីសិក្សាពុះពារតស៊ូ និងរៀនអំពីរបៀបនៃការរំដោះប្រទេសមែនទេ?

**ឆ៖** ជម្រាបគោរពលោកប្រធាន ខ្ញុំចង់ដឹងតើមាគ៌ាបដិវត្តន៍របស់ថៃគេដំណើរយ៉ាងម៉េច ដើម្បីទៅស្រាវជ្រាវចង់ដឹងសភាពការណ៍នៅប្រទេសថៃ។

[០៩:១៧:៥១]

**ស៖** ចាស អរគុណ។ ក្នុងអំឡុងពេលដែលលោកសិក្សានៅសាកលវិទ្យាធម្មសាត្រ ពេលនោះលោកបានបង្រៀន-- ពេលនោះសាលានោះបានបង្រៀនលោកពីការ ដូចថាបទពិសោធន៍ពីការចូលបម្រើក្នុងចលនាបក្ស។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកថា ពេលនោះហើយដែលលោកគិតថា ក្នុងនាមលោកជាអ្នករកផលប្រយោជន៍ឲ្យប្រជាពលរដ្ឋ ក្នុងនាមលោកជាអ្នកដូចថាជាអ្នកតស៊ូ ពេលនោះគឺលោកមានចិត្តមួយ លោកថាលោកលះបង់ ៗគំនិតមួយថា លោកលះបង់បម្រើផលប្រយោជន៍ប្រជាជនដោយផ្ទាល់ គឺដើម្បីក្នុងតួនាទីបម្រើជាតិ ពេលហ្នឹងហើយដែលថាជីវិតរបស់លោកហ្នឹងប្រឡូកក្នុងឆាកនយោបាយមែនទេ?

**ឆ៖** សូមគោរពលោកប្រធាន សូមសួរឲ្យខ្លីៗបន្តិច ពីព្រោះខួរក្បាលខ្ញុំឥឡូវវាយ៉ាប់ដែរ។

**ស៖** សូមអរគុណ។

**ឆ៖** សរុបឲ្យខ្លី។

**ស៖** ចាសៗ អរគុណលោក។ នាងខ្ញុំនឹងសង្ខេបសំណួរ នាងខ្ញុំចង់សួរលោកថា ពេលដែលលោករៀននៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ (ស៊ីក) ហ្នឹង លោកបានបង្រៀន និងរៀនដើម្បីបម្រើៗប្រជាជន និងលះបង់ផលប្រយោជន៍ គឺក្នុងគោលបំណងដើម្បីប្រទេសជាតិ។ ហើយខ្ញុំចង់ជម្រាបសួរលោកថា ទីកន្លែងនុ៎ងហើយ ដែលជាទីកន្លែងដែលផ្តល់ជីវិតនយោបាយជូនលោក មែនទេ?

[០៩:១៩:៣១]

**ជ៖** លោកប្រធាន មិនមែនកន្លែងហ្នឹងទេ។ គំនិតនយោបាយរបស់ខ្ញុំ វាចាប់កើតឡើងតាំងពីខ្ញុំអាយុបាន បួនដណ្ដប់ ប្រាំដណ្ដប់ឆ្នាំ។ ខ្ញុំសូមជម្រាបឲ្យវែងបន្តិច ពេលនោះខ្ញុំរស់នៅប្រទេសកម្ពុជា។ ខ្ញុំឃើញការជិះជាន់របស់ពួកបម្រើបារាំង វៃពួកកូនឈ្នួល វៃនឹងក្ដគោ វៃនឹងអីៗទាំងអស់។ ខ្ញុំកើតសង្វេគក្នុងចិត្ត ថា ឱ! មនុស្សយើងអើយ! វាមិនដឹងឯណា មនុស្សដូចសត្វតិរច្ឆាន។ ដូច្នោះដល់ប្រទេសថៃ ដល់បារាំងប្រគល់ប្រទេសថៃ ឲ្យ-- ប្រគល់ប្រទេស បាត់ដំបង សៀមរាប ស៊ីសុផុន ឲ្យថៃខ្ញុំចង់ដឹងតើនៅស្រុកថៃវាយ៉ាងម៉េច? បានជាខ្ញុំទៅរៀន ទៅរៀនឯណោះក៏មិនមែនរៀនកុម្មុយនីស្តទេ រៀនច្បាប់។ ក៏ប៉ុន្តែ ខ្ញុំឆ្លៀតឱកាសដើម្បីមើលសៀវភៅចម្រើន គឺសៀវភៅដែលនិយាយអំពីលទ្ធិកុម្មុយនីស្ត ហើយខ្ញុំក៏បានចាប់អារម្មណ៍គឺថា កុម្មុយនីស្តហ្នឹងគេជួយបណ្ដាប្រទេសដែលត្រូវជិះជាន់សង្កត់សង្កិន។ ដូច្នោះ ខ្ញុំចាប់អារម្មណ៍ពីរឿងហ្នឹង ហើយខ្ញុំបានខំរៀនបន្តិច ប៉ុន្តែឃើញថាវាឥតប្រយោជន៍បានជាខ្ញុំត្រឡប់មកប្រទេសកម្ពុជា មកតស៊ូរំដោះជាតិវិញ។ សូមជម្រាបលោកប្រធានប៉ុណ្ណឹង។

[០៩:២១:២៣]

**ស៖** ចាស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្ដី នួន ជា!

**លោក សុន អរុណ៖**

ខ្ញុំសូមសួរបញ្ជាក់ទៅមេធាវីខាងរដ្ឋប្បវេណី សូមបញ្ជាក់ម្ដងទៀតមកពីរឿងសាលាដែលលោក នួន ជា ទៅរៀនមិនមែនបញ្ញាសាស្ត្រទេ គឺធម្មសាត្រ។ សូមបញ្ជាក់ឲ្យច្បាស់ត្រង់ហ្នឹងកុំឲ្យច្រឡូកច្រឡំនឹងបញ្ញាសាស្ត្ររបស់យើង។ សូមអរគុណ។

[០៩:២១:៥១]

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណ។ នាងខ្ញុំជម្រាបសួរលោក នួន ជា អំមិញគឺសាលាធម្មសាត្រ មិនមែនជាសាលាបញ្ញាសាស្ត្រទេ។

**ស៖** ចាស ខ្ញុំសូមបន្តសំណួររបស់ខ្ញុំតទៅទៀត។ នៅឆ្នាំ១៩៥០ ពេលដែលលោកចូលរួមបក្សកុម្មុយនីស្តឥណ្ឌូចិន ពេលនោះលោកទទួលខុសត្រូវជាអ្នកបណ្ដុះបណ្ដាលមនោគមវិជ្ជាដែលហៅថា ដែលលោកច្រើននិយាយថា ទទួលផ្នែកអប់រំ មែនទេ?

**ឆ៖** សូមជម្រាប គោរពលោកប្រធាន ខ្ញុំមិនទាន់ទទួលតួនាទីអីធំដុំទេ ពេលនោះខ្ញុំនៅជាបក្ខជនធម្មតា។ ខ្ញុំទទួលខាងនាទីឃោសនា សរសេរកាសែត អប់រំ ហើយចុះទៅអប់ប្រជាជនតាមភូមិឃុំ ប៉ុណ្ណឹងទេ។

[០៩:២២:៤៧]

**ស៖** ចាស សូមអរគុណ។ ចុះក្នុងនាទីលោកដែលជាអ្នកដើរអប់រំ ខ្ញុំចង់ជម្រាបសួរលោកថា តើលោកយកឯកសារ ឬក៏មេរៀនណាដើម្បីយកទៅអប់រំប្រជាពលរដ្ឋ ឬក៏អ្នកតំណាងនៅក្នុងតំបន់ហ្នឹង?

**ឆ៖** សូមជម្រាប គោរពលោកប្រធាន តាមខ្ញុំចាំ កាលណោះការតស៊ូហ្នឹងវានៅក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលមានវៀតណាមត្រួតត្រា។ ដូច្នោះឯកសារហ្នឹងតាមខ្ញុំចាំ ប្រែពីឯកសារវៀតណាមមក មកខ្មែរ ហើយយកឯកសារហ្នឹងទៅអប់រំ គឺអប់រំអំពីបញ្ហា សំខាន់គេឲ្យអប់រំអំពីបញ្ហាសាមគ្គីជាតិខ្មែរ វៀតណាម លាវ ដើម្បីរំដោះឥណ្ឌូចិន។

**ស៖** ចាស សូមអរគុណ។ ចុះរាល់ឯកសារដែលបកប្រែពីភាសាវៀតណាមហ្នឹង មានបានឆ្លងកាត់ថ្នាក់ដឹកនាំណាខ្លះ មុននឹងលោកយកទៅផ្សព្វផ្សាយអប់រំហ្នឹង?

**ឆ៖** សូមគោរពលោកប្រធាន គ្មានឆ្លងកាត់ថ្នាក់ណាទេ គឺថ្នាក់គណៈអចិន្ត្រៃយ៍របស់ភូមិភាគជាវៀតណាម។ វៀតណាមគេចេះខ្មែរ។

[០៩:២៤:២០]

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា លោកបានធ្វើសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី០៥ ធ្នូ ២០១១ ឯកសារគឺ E1/16.1 ERNជាភាសាខ្មែរ 00758940 ERNជាភាសាអង់គ្លេស 00758850 ERNជាភាសាបារាំង 00758838។ ពេលនោះលោកថា "ខ្ញុំធ្វើសកម្មភាពប្រឆាំងនឹងអ្នកកាន់អំណាចថៃ ដែលជិះជាន់ប្រជាជន រួមជាមួយពួកអ្នកចម្រើនមួយចំនួន ដល់ក្រោយមកគេឃើញថា ខ្ញុំមានសកម្មភាពសកម្ម ក្នុងឆ្នាំ១៩៥០ ខ្ញុំបានចូលបក្សកុម្មុយនីស្តថៃ។ ចូលបក្សកុម្មុយ-នីស្តថៃដល់ថ្ងៃទី០៧ ខែកក្កដា ខ្ញុំសូមអនុញ្ញាតបក្សកុម្មុយនីស្តថៃមកធ្វើការតស៊ូនៅកម្ពុជា ដោយខ្ញុំឃើញបារាំងជិះជាន់សង្កត់សង្កិនប្រជាជនខ្ញុំ។ ហេតុដូច្នេះបក្សកុម្មុយនីស្តថៃក៏បានអនុញ្ញាតឲ្យលោកមកធ្វើការតស៊ូនៅប្រទេសកម្ពុជា។ ហើយខ្ញុំចង់ជម្រាបសួរលោកថា តើពេលដែលលោកមកធ្វើសកម្មភាពតស៊ូនៅស្រុកខ្មែរហ្នឹង លោកមានគ្នាប៉ុន្មាននាក់ដែរ?

[០៩:២៦:០១]

**ឆ៖** សូមគោរពលោកប្រធាន តាមខ្ញុំចាំ មាន១តែខ្ញុំម្នាក់ឯង។

**ស៖** ចាស អរគុណ។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកទៀតថា ពេលដែលថាលោកមកធ្វើសកម្មភាព លោកមានតែម្នាក់ឯង។ ចុះក្រោយពេលដែលលោកបានមកធ្វើសកម្មភាពតស៊ូនៅស្រុកខ្មែរហើយ ខ្ញុំចង់ជម្រាបសួរលោកថា តើលោកមានរាយការណ៍ពីសកម្មភាពស្រុកខ្មែរជូនបក្សកុម្មុយនីស្តថៃទេ?

**ឆ៖** សូមជម្រាប គោរពលោកប្រធាន គ្មានទេ ពីព្រោះដាច់ពីបក្សកុម្មុយនីស្តថៃមកហើយ មកចូលបក្សកុម្មុយនីស្តឥណ្ឌូចិន។ ដូច្នោះ ធ្វើសកម្មភាពអីក្រោមការដឹកនាំបញ្ជារបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលមានវៀតណាមត្រួតត្រា។

**ស៖** ចាស សូមអរគុណ។ សំណួរបន្តទៀត ខ្ញុំចង់ជម្រាបសួរលោកថា លោកបានអះអាងបន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ មកថា បក្សរបស់លោកមានមនុស្សនៅសេសសល់តែបី ឬបួននាក់ប៉ុណ្ណោះ។ ពេលនោះលោក ក្នុងបីបួននាក់នោះក៏មានលោកនៅក្នុងនុ៎ងដែរ ហើយពេលនុ៎ងហើយលោកបានរៀបចំ ដើម្បីបង្កើតបក្សហ្នឹងមែនទេ?

**ឆ៖** សូមគោរពលោកប្រធាន សូមជម្រាបឲ្យច្បាស់ មុនកិច្ចព្រមព្រៀងហ្សឺណែវ មិនមែនមានបីបួននាក់ទេ នៅសល់ពីរសាខា១បក្ស។ គឺសាខាត្រាំកក់ ហើយនិងសាខាឃុំពាម។ ដូច្នោះពេលនោះមានតា ទូ សាមុត, សាឡុត ស ហើយនិងខ្ញុំ គិតរៀបចំ។ បើអ៊ីចឹងទេបក្សប្រទេសកម្ពុជាយើងមុខតែរលាយហើយ។ ដូច្នោះត្រូវរៀបចំកសាងកម្លាំងឡើងវិញ។ សូមជម្រាបឲ្យច្បាស់។

[០៩:២៨:១៤]

**ស៖** ចាស អរគុណ។ ខ្ញុំជម្រាបសួរលោក មិនមែនជម្រាបសួរថាមុន១ កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវទេ ខ្ញុំចង់ជម្រាបសួរលោកថា បន្ទាប់ពីកិច្ចព្រមព្រៀងហ្សឺណែវក្នុងឆ្នាំ១៩៥៤ ពេលនុ៎ងបក្សរបស់លោក គឺនៅមានមនុស្សសេសសល់តែបី ឬបួននាក់ រួមទាំងលោកមែនទេ?

**ឆ៖** ត្រូវហើយ។

**ស៖** ចាស អរគុណ។ ខ្ញុំចង់ជម្រាបសួរថា ពេលដែលលោកនៅសល់មនុស្សតែបីបួននាក់ រួមទាំងលោកហ្នឹង។ ខ្ញុំចង់ជម្រាបសួរថា ដែលលោករៀបចំបក្សហ្នឹង លោករៀបចំនៅទិស នៅភូមិភាគណាខ្លះ?

**ឆ៖** សូមគោរពលោកប្រធាន រៀបចំតាំងពីព្រៃភ្នំ ចុងកាត់មាត់ញកមក តាំងពីឱរ៉ាល់, រលាក់

កងជើង, ប្រាំបីមុំ គឺរៀបចំតាំងពីព្រៃភ្នំមកចុះមកវាលរាប។ រៀបចំតាំងពីកសិករក្រចុះមក គឺយើងយកបង្អែកនៅព្រៃភ្នំ។

[០៩:២៩:២៧]

**ស៖** ចាស សូមអរគុណ--

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីសូមឲ្យយឺតបន្តិច ដើម្បីឲ្យអ្នកបកប្រែអាចតាមទាន់ក្នុងការបកប្រែ បើពុំនោះទេមានបញ្ហាបកប្រែ។

បើកក្បាលមេក្រូសិន!

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** អ៊ីចឹង ខ្ញុំសូមជម្រាបសួរលោកបន្តទៀតថា ដែលថាលោកបានរៀបចំតាំងពីតំបន់ វលាក់កងជើង រហូតហូរហែដែលលោករៀបរាប់។ ខ្ញុំចង់ជម្រាបសួរថា តំបន់ដែលលោករៀបចំហ្នឹង សួរថាលោកមានប្រគល់តួនាទីជាផ្នែកៗឲ្យអ្នកណាគ្រប់គ្រងទេ លោកពេលហ្នឹង?

**លោក នួន ជា៖**

[០៩:៣០:០៩]

**ជ៖** ពេលហ្នឹង មិនបានប្រគល់នាទីឲ្យ-- គោរពលោកប្រធាន ពេលហ្នឹងមិនប្រគល់នាទីឲ្យអ្នកណាគ្រប់គ្រងទេ មានតែកម្មាភិបាលចាស់ ដែលគេតស៊ូពីមុននោះ ម្នាក់ពីរនាក់ប៉ុណ្ណឹងទេ ហើយរួមគ្នាធ្វើទៅ មិនមែនទាន់ប្រគល់មាននាទីអីឲ្យច្បាស់លាស់ គ្មានទេ។

**ស៖** ចាស សូមអរគុណ។ ខ្ញុំសូមសួរលោកបន្ត។ ពេលដែលលោក-- លោកបានធ្វើសេចក្ដីថ្លែងការណ៍កាលពីក្នុងសវនាការ លើសេចក្ដីសន្និដ្ឋានលើបទចោទប្រកាន់កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោងបួនដប់មួយនាទីដប់ប្រាំវិនាទី ថា “ក្នុងខែសីហា ឆ្នាំ១៩៦២ បក្សសម្រេចចិត្តតស៊ូនយោបាយដោយរួមផ្សំអាវុធ” មែនទេលោក?

**ជ៖** សូមជម្រាប គោរពលោកប្រធាន។ ឆ្នាំ១៩៦២ ហ្នឹង ជាមហាសន្និបាតបក្សលើកទី១ អំលើកទី២ បានសម្រេចតស៊ូរួមផ្សំនយោបាយ និងអាវុធ ដោយយកនយោបាយជាមូលដ្ឋាន មិនមែនយកអាវុធជាសំខាន់ទេ អាវុធនេះគ្មានអីទេ មានតែកាំបិត ពូថៅ ដំបង។ ដូច្នោះ គ្រាន់តែការពារខ្លួន ប៉ុណ្ណឹងទេ។

**ស៖** ចាស សូមអរគុណ។ អ៊ីចឹង វិធីសាស្ត្រ នៃការប្រយុទ្ធរបស់លោកគឺប្រើអាវុធ និងដំបង។ អ៊ីចឹងលោកណ៎ា! អរគុណ។ អ៊ីចឹងគោលដៅដែលលោកតស៊ូ ដែលធ្វើបដិវត្តន៍ហ្នឹងនៅតំបន់ណាដែរ?

**ជ៖** គោរពលោកប្រធាន នៅខាងផ្នែកពាយ័ព្យទិស។

[០៩:៣២:២៥]

**ស៖** ចាស សូមអរគុណ។ ចុះអ្នកណាជាអ្នកដឹកនាំការប្រយុទ្ធហ្នឹង?

**ជ៖** ការប្រយុទ្ធហ្នឹង កាលណោះមានតែបីនាក់ទេ មានលោកតា ទូ សាមុត, សាឡុត ស ហើយនិងខ្ញុំ។

**ស៖** ចាសៗ សូមអរគុណ។ ចុះលោក ខ្ញុំចង់ជម្រាបសួរលោកបន្តថា តើមានការឧបត្ថម្ភ និងស្បៀងពីណាមកដែរ ពេលហ្នឹង?

**ជ៖** ពេលហ្នឹង ការឧបត្ថម្ភសុំអង្ករពីប្រជាជន។ សុំស្បៀងពីប្រជាជន ហើយបាញ់សត្វ បាញ់ឈ្លូស បាញ់ជ្រូកព្រៃ ជ្រូកអីហ្នឹងទទួលទានទៅ។

**ស៖** ចាស សូមអរគុណ។ ចុះក្នុងពេលអំឡុងពេលហ្នឹងដែរ តើលោកទទួលតួនាទីអ្វីដែរ?

**ជ៖** ពេលហ្នឹង ខ្ញុំមិនទាន់មានតួនាទីអីច្បាស់លាស់ទេ គ្រាន់តែអ្នកដើរឃោសនាអប់រំ ឲ្យប្រជាជនភ្ញាក់រឭក ពីព្រោះប្រជាជននៅចុងកាត់មាត់ញកហ្នឹង ដូចជ្រាបស្រាប់ហើយ ខ្ញុំមិនមើលងាយទេ ប៉ុន្តែថា ផ្ទះណាក៏មានបិតស្រាដែរ ពីព្រោះស្រុកហ្នឹងវាត្រជាក់ វាចាញ់។ ដូច្នោះស្រវឹងស្រារាល់តែថ្ងៃហ្នឹង ដូច្នោះ ទាល់តែអប់រំម្តងបន្តិចៗ។

[០៩:៣៣:៥៦]

**ស៖** ចាស សូមអរគុណ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកថា ក្នុងអំឡុងពេលហ្នឹង ចំពោះរឿងស្លៀកពាក់ ពេលនោះប្រជាជនស្លៀកពាក់ពណ៌ខ្មៅមែនទេ?

**ជ៖** បាទ សូមគោរពលោកប្រធាន អត់ទេ មានអីទេ ជួនណាមានខោខ្លីមួយ ក្រមាមួយប៉ុណ្ណឹងទេ ព្រោះក្រណាស់។ ទៅចុងកាត់មាត់ញកមានអី រកតែសំពត់ថ្មីស្លៀកគ្មានផង។

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា នៅខែមីនា ឆ្នាំ៧៥ បក្សវៀត-ណាមបានស្នើជួបបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យមែនទេ ដែលលោកបានជម្រាបកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ហ្នឹង? មែនទេលោក?

**ជ៖** គោរពលោកប្រធាន សូមបញ្ជាក់ថ្ងៃខែឲ្យច្បាស់បន្តិចមើល ខ្ញុំចាំ-- កុំលឿនពេកខ្ញុំភ្លាប់ថ្ងៃ

ខែមិនទាន់ទេ។

[០៩:៣៥:១០]

**ស៖** ចាស ខ្ញុំចង់ជម្រាបសួរលោកថានៅក្នុងខែមីនា ឆ្នាំ១៩៧៥ បក្សវៀតណាមបានស្នើជួប បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យមែនទេ? សេចក្តីថ្លែងការណ៍នោះលោកថ្លែងជាមួយសហព្រះរាជ អាជ្ញាកាលពីម្សិលមិញ។ សូមអរគុណ។

**ឆ៖** គោរពលោកប្រធាន មានស្នើជួប គឺ ង្វៀន វ៉ាន់ លិញ។

**ស៖** សូមអរគុណ។ តើពេលនោះ អ្នកណាជាអ្នកជួបវៀតណាមហ្នឹង?

**ឆ៖** ពេលហ្នឹងខ្ញុំ។

**ស៖** លោកជាអ្នកជួប។ តើការជួបហ្នឹងនិយាយអំពីអ្វីដែរលោក?

**ឆ៖** ការជួបហ្នឹង-- គោរពលោកប្រធាន។ គេចង់ដឹងសភាពការណ៍ អំពីប្រទេសកម្ពុជាវាយ៉ាង ម៉េច។

**ស៖** សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្តទៀត កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ឯកសារ E1/22.1 ERN ជាភាសាខ្មែរ 00761403 ERN ជាភាសាអង់គ្លេស 00762188 ERN ជាភាសា បារាំង 00762288។ ពេលនោះលោកបានធ្វើសេចក្តីថ្លែងការណ៍ថា "បក្សកុម្មុយនីស្តកម្ពុជាគ្មានមាគ៌ា នយោបាយប្រឆាំងនឹងសម្តេចព្រះ នរោត្តម សីហនុ ទេ មានតែមាគ៌ាគោរពអញ្ជើញ សូមឲ្យព្រះអង្គ អង្គាល់នុំងឡើងតំណែងជាប្រធានគណៈប្រធានរដ្ឋ" គឺជាអំណាចខ្ពស់បំផុតមែនទេ?

[០៩:៣៧:២៧]

**ឆ៖** គោរពលោកប្រធាន មែន!

**ស៖** ចាស សូមអរគុណ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកថា ពាក្យដែលថា "គណៈប្រធានរដ្ឋ មានអំណាចខ្ពស់បំផុត" នោះ តើមានន័យយ៉ាងណាដែរ? សូមលោកជម្រាបអង្គសវនាការ។

**ឆ៖** សូមគោរពលោកប្រធាន គណៈប្រធានរដ្ឋមិនមែននាទីខាងខ្ញុំទេ គឺគណៈប្រធានរដ្ឋនេះ គឺ ខាងលោក ខៀវ សំផន។ ខ្ញុំខាងផ្សេងទេ ខ្ញុំខាងសភា។

[០៩:៣៨:០៨]

**ស៖** សូមអរគុណ។ អ៊ីចឹងតាមខ្ញុំយល់ពាក្យថា "គណៈប្រធានរដ្ឋ" គឺអំណាចមួយដែលខ្ពស់ បំផុតដែលលោក ដែលក្រុមខាងលោកហ្នឹងបានប្រគេនជូនព្រះអង្គមែនទេ?

**ឆ៖** មិនមែនទេ ប្រជាជនទាំងមូល។

**ស៖** ចាស សូមអរគុណ។ ខ្ញុំសូមជម្រាបសួរលោកពីរបីសំណួរទៀតទេ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកថា លោកបានធ្វើសេចក្ដីថ្លែងការណ៍កាលពីថ្ងៃទី៣០ ខែ១ ២០១១ ម្សិលមិញហ្នឹងជាមួយសហព្រះរាជអាជ្ញាអន្តរជាតិថា ក្នុងការប្រជុំប្រាំដងៗហ្នឹងមាននិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ ក៏ប៉ុន្តែលោកមិនបានចាំថ្ងៃខែឆ្នាំ មែនទេ?

**ឆ៖** មែន គោរពលោកប្រធាន។

[០៩:៣៩:០១]

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំចង់-- ខ្ញុំសូមសួរលោកបន្តទៀតថា តើបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យហ្នឹងតស៊ូរហូតមកដែលកំណត់ថា សត្រូវហ្នឹង ខ្ញុំចង់ជម្រាបសួរថា តើនរណាខ្លះដែលជាសត្រូវដែលក្រុមខាងលោកកំណត់ថាជា “សត្រូវ” ហ្នឹង?

**ឆ៖** សូមកែពាក្យលោកស្រីបន្តិច មិនមែនបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យទេ បក្សកុម្មុយនីស្តប្រជាជនកម្ពុជាទទេទេ គ្មានប្រជាធិបតេយ្យទេ ពីព្រោះវាហួសទៅហើយ។

**ស៖** ចាស ឥឡូវតាមលោកចុះថា បក្សកុម្មុយនីស្តប្រជាជន។ ខ្ញុំចង់សួរថា បក្ស--

**ឆ៖** បក្សៗ មិនមែនបក្សកុម្មុយនីស្តប្រជាជនទេ បក្សប្រជាជនបដិវត្តន៍កម្ពុជា។

[០៩:៣៩:៥៥]

**ស៖** បក្សប្រជាជនបដិវត្តន៍កម្ពុជា ពេលនុ៎ងលោក ពេលក្នុងអំឡុងពេលដែលលោកតស៊ូនៅក្នុងបក្សប្រជាជនបដិវត្តន៍កម្ពុជា ខ្ញុំចង់ជម្រាបសួរថា ពេលនុ៎ងដែលលោកកំណត់ថា ជាសត្រូវហ្នឹងៗជានរណាខ្លះទៅ ដែលលោកកំណត់ជាសត្រូវហ្នឹង?

**ឆ៖** សូមគោរពលោកប្រធាន ការកំណត់ជាសត្រូវ ក្នុងពេលនោះ គឺបរទេសដែលឈ្លានពានវាតទី លេបទឹកដី បំបាត់ពូជសាសន៍កម្ពុជា។ អានេះសត្រូវពីក្រៅ។ ឯសត្រូវខាងក្នុងគឺពួកសក្ដិភូមិបរិវារចក្រពត្តិ ឃោរឃៅផុតលេខ ធ្វើបាបប្រជាជន ហើយក្បត់ជាតិ។

**ស៖** ចាស សូមអរគុណ។ ពាក្យថា “សក្ដិភូមិ” សក្ដិភូមិ គឺលោកកំណត់ត្រឹមណា? ដែលថាកំណត់ថាជាសក្ដិភូមិហ្នឹង?

**ឆ៖** សក្ដិ-- សូមគោរពលោកប្រធាន ពាក្យថា “សក្ដិភូមិ” មិនមែនស្ដេចទេ សក្ដិភូមិហ្នឹងគឺម្ចាស់ដី ឯម្ចាស់ដីហ្នឹងមានច្រើនប្រភេទ។ ម្ចាស់ដីឃោរឃៅ ម្ចាស់ដីថ្នាក់ក្រោម ម្ចាស់ដីកណ្ដាល

ហើយនិងម្ចាស់ដីដែលជិះជាន់ប្រជាជន។ ដូច្នោះពាក្យម្ចាស់ដីមួយម៉ាត់ហ្នឹង វាបែងចែកទៅជាបីប្អូនចំណែកទៅទៀត។

[០៩:៤១:៥៣]

**ស៖** ចាស ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា បក្សកុម្មុយនីស្តកម្ពុជាដែលលោកនិយាយហ្នឹង ខ្ញុំចង់សួរថា បក្សកុម្មុយនីស្តកម្ពុជាដែលថាកំណត់ថាដែលជាវណ្ណៈមួយដែលថាល្អឥតខ្ចោះ ដូចថាល្អបំផុតហ្នឹង គឺកំណត់ត្រឹមណា លោក?

**ឆ៖** សូមគោរពលោកប្រធាន កំណត់បក្សកុម្មុយនីស្តកម្ពុជាល្អឥតខ្ចោះហ្នឹង អាហ្នឹងវាលើទ្រឹស្តីទេ ក៏ប៉ុន្តែក្នុងការប្រតិបត្តិហ្នឹង វាមានអ្នកខូចដែរ មានអ្នកល្អភាគច្រើន ក៏ប៉ុន្តែក្រៅពីនេះក៏មានអ្នកមិនល្អដែរ។ ដូច្នោះ វាមិនមែនទាំងអស់គ្នា បក្ខជនកុម្មុយនីស្តវាមិនមែនល្អទាំងអស់គ្នាទេ។ សូមជម្រាបលោកប្រធាន។

**ស៖** ចាស សូមអរគុណ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកមួយទៀតថា តើពេលអំឡុងពេលដែលប៉ុល ពត ទៅព្យាលបាលជំងឺនៅហាណូយ ក្រោយមកគាត់ចេញទៅប៉េកាំង។ ខ្ញុំចង់ជម្រាបសួរថា តើប៉ុល ពត ចេញទៅប៉េកាំងហ្នឹង ក្នុងឆ្នាំណាដែរ លោក?

[០៩:៤២:៤៥]

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនចាំទេ ដូចជាក្រោយៗពីគាត់ចេញពីហាណូយទៅហើយ ដូចជាឆ្នាំ-- ខ្ញុំមិនចាំឆ្នាំទេ។

**ស៖** ប្រហែលឆ្នាំ៦៥ ទេ លោក?

**ឆ៖** ប្រហែល។

**ស៖** ចាស អរគុណ។ ចុះពេលលោកមានដឹងទេ ពេលដែលគាត់ទៅ គាត់ទៅធ្វើអីដែរ?

**ឆ៖** គោរពលោកប្រធាន ពេលដែលគាត់ទៅហ្នឹង មួយទៅអាឆ្នាំ៦៥ ហ្នឹងគាត់ទៅដំបូង។ ពួកយកមាគ៌ានយោបាយយុទ្ធសាស្ត្រ មាគ៌ានយោបាយយុទ្ធវិធី យកទៅឧទ្ទេសនាមឲ្យបក្សកុម្មុយនីស្តវៀតណាមគេយល់ ហើយរួចទៅ យកទៅឧទ្ទេសនាមទៅឲ្យចិនគេយល់ ព្រោះកាលនោះបក្សយើងវានៅតូច មិនមានទាន់មានអ្នកណាគេទទួលស្គាល់ទេ។ ដូច្នោះបានជាខំផ្សាយមាគ៌ានយោបាយយុទ្ធសាស្ត្រ យុទ្ធវិធីឲ្យគេយល់។

[០៩:៤៣:៥២]

**សៈ** ចាស សូមអរគុណ។ គាត់ទៅតែម្នាក់ឯងគាត់ ឬក៏ទៅមានគ្នាប៉ុន្មាននាក់ដែរ លោក?

**ឆៈ** ដំបូងតាម-- គោរពលោកប្រធាន គាត់ទៅម្នាក់ឯង ហើយមានកងការពារពីរនាក់។

**សៈ** ចុះក្រោយបន្តបន្ទាប់ទៀត?

**ឆៈ** ក្រោយបន្តបន្ទាប់ទៀត គាត់ក៏ទៅម្នាក់ឯងដែរ។

**សៈ** ចាស សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា នៅពេលដែលវៀតណាម លោកបាន នៅពេលដែលវៀតណាមមិនព្រមផ្តល់អាវុធឲ្យលោកក្នុងឆ្នាំ១៩៦៨ លោកៗបានប្រាប់ឲ្យ សោ ភឹម ទៅលួចអាវុធវៀតណាម លួចអាវុធវៀតណាម ដែលធ្វើឃ្លាំកម្ពុល់ទុកហ្នឹងមែនទេ លោក?

[០៩:៤៤:៥០]

**ឆៈ** ខ្ញុំ-- គោរពលោកប្រធាន ខ្ញុំមិនបានប្រាប់ឲ្យ សោ ភឹម ទៅលួចទេ។ ប៉ុន្តែអាវុធនេះ ជាអាវុធរបស់ខ្មែរ មិនមែនអាវុធរបស់វៀតណាមទេ។ អាវុធដែលចិនគេជួយមក ហើយដាក់នៅដីខ្មែរ ឯវៀតណាមទេ ដែលមកលួចយកអាវុធរបស់ខ្មែរនោះ។

**សៈ** សូមអរគុណ។ អ៊ីចឹងជាសំណួរចុងក្រោយ ខ្ញុំសូមជម្រាបសួរលោកថា តើក្រុមប្រជាជនដែលបានធ្លាប់ចោទប្រកាន់លោកពីទំនាក់ទំនងនៃការទទួលប្រាក់ពីវៀតណាមដែរឬទេ?

**ឆៈ** គោរពលោកប្រធាន មិនដែលបាន-- បក្សកុម្មុយនីស្តកម្ពុជាមិនដែលបានទទួលប្រាក់ពីវៀតណាមទេ។

**សៈ** សូមអស់សំណួរ សូមអរគុណលោក នួន ជា។

**ប្រធានអង្គជំនុំៈ**

អញ្ជើញ ដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ!

[០៩:៤៦:២៣]

**លោក បាណាបេ ណេគ្រីៈ**

លោកប្រធាន ខ្ញុំមិនទទួលបានការបកប្រែអ្វីដែលលោកបានលើកឡើងអម្បាញ់មិញនេះទេ។ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំសួរចម្លើយលោក នួន ជា ដែរឬទេ?

**ប្រធានអង្គជំនុំៈ**

សូមអញ្ជើញលោកមេធាវី!

**សួរដោយលោក បាណាបេ ណោគ្វី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក នួន ជា។

**ស៖** លោក នួន ជា សហភាតារបស់ខ្ញុំបានចោទសួរលោកអម្បាញ់មិញ ឥឡូវនេះខ្ញុំសូមធ្វើការអត្ថាធិប្បាយលើសម្រង់នៃពាក្យពេចន៍របស់លោក ដែលលោកបានធ្វើនៅថ្ងៃទី ២២ វិច្ឆិកា ឆ្នាំ២០១១។ ខ្ញុំគិតថា ខ្ញុំត្រូវតែផ្តល់ឲ្យយោងនៃឯកសារនេះ គឺលេខ E1/14.1 ហើយលេខ ERN គឺជាភាសាបារាំងគឺ 00756280 ទៅដល់ 0075 និងលេខចុងកន្ទុយលេខ 20។ ជាភាសាអង់គ្លេសគឺ 00756140 ទៅដល់ 00756176 ហើយជាភាសាខ្មែរគឺ 00755342 ទៅដល់ 00755365។ សម្រង់ទីមួយនេះ ដែលខ្ញុំចង់ធ្វើអត្ថាធិប្បាយជាមួយលោក លោក នួន ជា គឺនិយាយអំពីការពិចារណារបស់លោក ដែលលោកបានធ្វើជាមួយគណៈកម្មាធិការមជ្ឈិម នៅខែឧសភា ឆ្នាំ១៩៧៤ លើផលវិបាកនៃការលុបបំបាត់ចោលនូវរូបិយប័ណ្ណ។ លោកបាននិយាយថា ដូចតទៅនេះ៖ គឺលេខ ERN 0075363 លោកបាននិយាយថា បទពិសោធន៍បានបង្ហាញថា នៅក្នុងតំបន់រំដោះ យើងអាចមិនចាយលុយបាន ហើយនិងយើងអាចដំណើរការបាន។ លោក នួន ជា ខ្ញុំសូមអញ្ជើញលោកពន្យល់ដល់អង្គសវនាការថា តើបទពិសោធន៍នុំងបានធ្វើឡើងតាមរបៀបណា? ហើយតើលោកបានគ្រប់គ្រងតំបន់រំដោះនោះដោយមិនប្រើការលុយកាក់យ៉ាងដូចម្តេចបានទៅ?

[០៩:៤៩:៤០]

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន បញ្ហានេះមិនមែនលុបចោលរូបិយប័ណ្ណរហូតទេ។ ក៏ប៉ុន្តែពេលនោះ យើងមិនទាន់បង្កបង្កើនផលអីបានពេញលេញផងទេ នៅតាមតំបន់រំដោះ ពីព្រោះកប៉ាល់ហោះអាមេរិកវាទម្លាក់គ្រប់បែកច្រើនណាស់។ ដូច្នោះប្តូរការដោះដូរគ្នាទេ ហើយពេលនោះក៏មានសល់ស្បៀងខ្លះដែរ មិនមែនអស់ទេ ល្មមចិញ្ចឹមគ្នាបាននៅក្នុងភូមិនោះ។ អ៊ីចឹងហើយបានជាមានគំនិតចាត់តាំងជាសមាគមស្រូវ សមាគមជួយសង្គ្រោះគ្នា។ គោរពលោកប្រធាន មានប៉ុណ្ណឹង។

**ស៖** សូមអរគុណលោក នួន ជា។ លោកនៅក្នុងឯកសារដដែលនេះ លោកបានអធិប្បាយបទពិសោធន៍នៅក្នុងតំបន់រំដោះនេះថា សត្រូវពុំអាចមានសមត្ថភាពក្នុងការវាយប្រហារយើង ឬដណ្តើមតំបន់រំដោះនេះបានទេ។ ប៉ុន្តែផ្ទុយទៅវិញ គឺថាយើងអាចពង្រីកតំបន់រំដោះនេះបានទៀតផង។ ហើយពួកអ្នកស៊ើបអង្កេតហ្នឹងមិនអាចទិញកម្មាភិបាល និងកូនទាហានរបស់យើង។ អ៊ីចឹងយើងអាចធ្វើឲ្យ

តំបន់ផ្សេងទៀតក្លាយជាតំបន់រំដោះផងដែរ។ សំណួរខ្ញុំដូចតទៅនេះ តើយើងត្រូវយល់ពាក្យពេចន៍របស់លោកទាំងអស់នេះ យ៉ាងដូចម្ដេច? តើនេះមិនមែនបានន័យថា នៅក្នុងតំបន់រំដោះនេះ លោកបានសម្រេចចិត្តថា មិនប្រើថវិកាដើម្បីឲ្យគ្រប់គ្រងតំបន់ទាំងអស់នេះឲ្យបានល្អ ឬក៏យ៉ាងម៉េច? ប្រសើរឬក៏យ៉ាងម៉េច?

[០៩:៥២:០៦]

**ជ៖** សូមគោរពលោកប្រធាន ពេលហ្នឹងតំបន់រំដោះដោយកន្លែង កន្លែងខ្លះបើមានចាយលុយនោះ ពួកគិញ ពួកចារកម្ម របស់អាមេរិកក្ដី របស់វៀតណាមក្ដីវាប្រើលុយដើម្បីទិញកម្មាភិបាលយើង។ ដល់យើងឈប់ ដល់យើងផ្អាកមិនចាយលុយទៅវាមិនដឹងជាយកអីទៅប្រើ។ ដូច្នោះបានជាយើងរក្សាតំបន់រំដោះយើងបាន ហើយចេះតែពង្រីកតំបន់រំដោះយើងបានម្ដងបន្តិចៗជាបណ្ដើរៗទៅ។ បើកាលណាមានចាយលុយគ្រោះថ្នាក់ធំហើយ ព្រោះកម្មាភិបាលធម្មតាទេ រឿងលុយជូនណាគោលជំហរល្អ ក៏ប៉ុន្តែដល់ជួបលុយទៅវាទន់ជ្រាយទៅ វាទៅបម្រើខ្មាំងក៏មាន។ កម្មាភិបាលមិនមែនល្អទាំងអស់ទេ។

[០៩:៥៣:៣៨]

**ស៖** បាទសូមអរគុណ។ បើអ៊ីចឹង តើនេះមានន័យថា នៅក្នុងតំបន់រំដោះគឺលោកបានបង្ខំគ្រប់ទិសទីបង្កើតឲ្យមានសហករណ៍ តើមែនដែរឬទេ?

**ជ៖** សូមគោរពលោកប្រធាន មិនមែនបង្ខំទេ ដោយការស្ម័គ្រចិត្តអធិប្បាយឲ្យគេយល់អំពីសារៈសំខាន់របស់សហករណ៍ វាមានសារៈសំខាន់យ៉ាងម៉េច? ជួយឧបត្ថម្ភគ្នាយ៉ាងម៉េច? បើយើងមិនចាត់តាំងសហករណ៍ទេ ពួកអ្នកដែលម្ចាស់ដីឃោរឃៅអីៗហ្នឹងវាឲ្យខ្ចីស្រូវ ឲ្យបុលលុយបុលកាក់អីហ្នឹង វាយកការថ្លៃណាស់ ដូចជា ឧបមាស្រូវខ្ចីដប់ថាំងយកការមានតែប្រាំថាំងអីឯណោះ។ ដូច្នោះធ្វើស្រែពួកអ្នកស្រែក្រធ្វើស្រែបម្រើតែគេអ្នកមាន។

**ស៖** ដូច្នេះយើងអាចនិយាយបានទេថា ប្រព័ន្ធសម្ហូហភាពនេះ គឺជាធាតុសំខាន់បំផុតនៃបន្ទាត់នយោបាយ និងយុទ្ធសាស្ត្ររបស់លោកនៅសម័យនុ៎ង។ តើមែនដែរឬទេ?

**ជ៖** គោរពលោកប្រធាន។ សូមលោកសួរឲ្យច្បាស់បន្តិចមើល។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរចុងក្រោយអំមិញម្ដងទៀត ពីព្រោះជនជាប់ចោទស្ដាប់សំណួររបស់លោកមិនយល់ច្បាស់ទេ។ អ៊ីចឹងវាលំបាកក្នុងការឆ្លើយតប។

**សួរដោយលោក បាណាបេ ណេគ្វី៖**

**ស៖** បាទ លោកប្រធានខ្ញុំចោទសំណួរឡើងវិញ។ លោក នួន ជា ខ្ញុំចង់ដឹងថា តើយើងអាចបញ្ជាក់បានទេថា ប្រព័ន្ធសហករណ៍ ឬក៏សមូហភាពនេះ សមូហភាពដីទាំងអស់នេះ គឺជាគុស័ខាន់បំផុតនៃមាគ៌ានយោបាយ និងយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា។ តើមែនដែរឬទេ?

[០៩:៥៦:២៥]

**ឆ៖** សូមគោរពលោកប្រធាន មិនមែនសហករណ៍ហ្នឹងវាសំខាន់បំផុតទេ សំខាន់គឺមាគ៌ានយោបាយ យុទ្ធសាស្ត្រ យុទ្ធវិធីរបស់បក្សទេ ដែលសំខាន់បំផុត។ ឯសហករណ៍វាគ្រាន់តែជារូបភាព--ជារូបធម៌។ ប៉ុន្តែដែលសំខាន់ គឺនាមធម៌ គឺមាគ៌ានយោបាយយុទ្ធសាស្ត្រ យុទ្ធវិធី។

**ស៖** តើលោកចាំទេ លោក នួន ជា ចាំទេថា នៅក្នុងតំបន់រំដោះទាំងអស់នេះ ដែលលោកបានលើកថា បានជំរុញឲ្យបង្កើតសហករណ៍ តើនៅសម័យនោះផ្សារទាំងអស់នោះត្រូវបានបង្កឲ្យមានបញ្ហាដោយសារការរំខានរបស់វៀតណាម ហើយបង្កឲ្យមានកង្វះអាហារជាដើម។ តើមែនដែរឬទេ?

[០៩:៥៧:៤៨]

**ឆ៖** ខ្ញុំសូមគោរពលោកប្រធាន បើកាលណាមិនចាត់តាំងសហករណ៍ វៀតណាមប្រមូលទិញទាំងអស់ ពីព្រោះកាលនោះកងទ័ពវៀតណាមចូលសឹងពេញប្រទេសកម្ពុជាទៅហើយ។ ដូច្នោះជញ្ជូនអង្ករដូចជាស្រមោច ដូចជាសង្ការជញ្ជូនអង្ករអីចឹង យកទៅចិញ្ចឹមវៀតណាមនោះ។ ដល់ពិនិត្យឃើញអីចឹងទៅ បានជាគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា បើយើងគ្មានវិធីទប់ទល់ទេ យើងគ្មានអីចិញ្ចឹមប្រជាជនយើង ចិញ្ចឹមកងទ័ពយើងទេ។ វៀតណាមគេមានលុយ គេទិញ ប្រមូលទិញអស់ហើយ។ នេះខ្ញុំសូមជម្រាបលោកប្រធាន។

[០៩:៥៨:៥២]

**ស៖** តើលោកចាំទេថា កាលនៅសម័យនោះទាក់ទងទៅនឹងសមាសភាពវៀតណាមនោះ លោកបានពិភាក្សាៗអំពី ជាមួយនឹងលោក យិន វ៉ាន់ លិញ ដែលជាអ្នកដឹកបក្សកុម្មុយនីស្តកម្ពុជា ដែលនៅសម័យនោះ?

**ឆ៖** សូមគោរពលោកប្រធាន មិនមែន យិន វ៉ាន់ លិញ ទេ គឺ ង្វៀន វ៉ាន់ លិញ ពិភាក្សាច្រើនបញ្ហា។ លោកចង់សួរថា តើខ្ញុំពិភាក្សា លោកចង់សួរឲ្យថា ពិភាក្សាពីរឿងអី? ពីព្រោះពិភាក្សាវាច្រើន។ វាមានជួនណាវៀតណាមមករំលោភលើអធិបតេយ្យភាពរបស់ខ្មែរ ទិញអីៗមិនសួរខ្មែរ ប្រើអំណាច

ជិះជាន់ប្រជាជនខ្មែរ។ ដូច្នោះបានជាហៅ ង្វៀន វ៉ាន់ លិញ ហើយនិងខ្ញុំនេះទៅពិភាក្សាគ្នាដើម្បីសម្រួល ព្រោះខ្មែរហ្នឹងមិនចូលចិត្តវៀតណាមទេ តាំងពីសម័យណាមក។ ទើបនឹងមកក្រោយទេ ដែលបក្ស កុម្មុយនីស្តកម្ពុជាសម្រួលថា យើងកុំហៅវៀតណាមជាសត្រូវស្លូតបូត យើងត្រូវហៅថា មិត្តមានទំនាស់ អានេះជាមតិរបស់ ប៉ុល ពត។ ឯទំនាស់នេះទំនាស់ធំដែរ មិនមែនទំនាស់តូចទេ ក៏ប៉ុន្តែបើហៅសត្រូវ ស្លូតបូត វាដូចជាហួសពេក។

[១០:០១:០២]

**ស៖** បាទ សូមអរគុណលោក នួន ជា។ តើជាការត្រឹមត្រូវដែរឬទេ យើងអាចនិយាយថា រវាង ទំនាស់ដែលលោកពិភាក្សាជាមួយលោក ង្វៀន វ៉ាន់លិញ នេះ គឺថា លោកបានបញ្ចប់នូវឧបទ្ទវហេតុ រវាងកងទ័ពរបស់លោក កុយ ធួន ហើយនិងកងទ័ពវៀតណាមនៅក្នុងខេត្តក្រចេះ។ តើមែនដែរឬទេ?

**ជ៖** ជម្រាបគោរពលោកប្រធាន បញ្ចប់ដោយប្រើកម្លាំងប្រជាជន មិនមែនបញ្ចប់ដោយ អាវុធទេ គឺប្រជាជនមិនរាប់រកមិនហៅរកវៀតណាម ដែលចូលមកប្រទេសកម្ពុជា ហើយមិនឧបត្ថម្ភ អីៗទាំងអស់។ ដូច្នេះវៀតណាម ត្រូវគោរពរដ្ឋអំណាចការពិភាក្សាគ្នាអ៊ីចេះ ដល់ទៅធ្វើវាអ៊ីចុះ។ អាហ្នឹងការទាក់ទងការទូតចរចាជាមួយវៀតណាមហ្នឹង ខាងគណៈកម្មការភូមិភាគនិយាយឲ្យច្បាស់ លាស់ចុះ ស្មើរតែក្លួតឈាម និយាយអ៊ីចេះធ្វើអ៊ីចុះ និយាយអ៊ីចុះធ្វើអ៊ីចេះ។

**ស៖** អ៊ីចឹងតើជាការត្រឹមត្រូវដែរឬទេ អាចសេចក្តីសម្រេចថា បិទទីផ្សារនៅតំបន់រំដោះនោះ គឺជាមធ្យោបាយក្នុងការបញ្ចប់ នៃការអត់សណ្តាប់ធ្នាប់ នៃសមាសភាពវៀតណាម ដែលបង្កក្នុងទឹកដី របស់លោកនោះ តើមែនដែរឬទេ?

**ជ៖** គោរពលោកប្រធាន មែន! ព្រោះវៀតណាមអត់ផ្សារមិនបានទេ។

[១០:០៣:២៣]

**ស៖** ហើយក្នុងឱកាសជាមួយគ្នានេះដែរ គឺថាលោកដោះស្រាយ និងពង្រឹងការតស៊ូប្រឆាំងនឹង វណ្ណៈជិះជាន់។ តើត្រឹមត្រូវដែរឬទេ?

**ជ៖** សូមសួរលោក លោកនិយាយថា វណ្ណៈជិះជាន់ហ្នឹង វណ្ណៈណា?

**ស៖** លោកខ្លួនឯងផ្ទាល់ លោកបានឆ្លើយទៅសហភាតារបស់ខ្ញុំគឺថា លោកបាននិយាយ អម្បាញ់មិញថា សក្តិភូមិ តើនេះគឺជាការតស៊ូនឹងពួកវណ្ណៈសក្តិភូមិមែនឬទេ?

**ឆ៖** គោរពលោកប្រធាន បើនិយាយពីពាក្យ សក្តិភូមិមួយម៉ាត់ហ្នឹង វាមិនត្រូវទេ គឺប្រឆាំងនឹងពួកសក្តិភូមិឃោរឃៅ កាចឃោរឃៅជិះជាន់ប្រជាជន។ អាហ្នឹងគឺប្រឆាំង ការប្រឆាំងនេះ មិនមែនទៅសម្លាប់អីទេ គឺទាមទារឲ្យគេបន្ថយឈ្នួលស្រែ ការប្រាក់។ អានេះហៅថា ប្រឆាំងដែរ។

[១០:០៥:០៦]

**ស៖** បាទសូមអរគុណដែលបានបំភ្លឺ។ នៅពេលដែលសហករណ៍ទាំងអស់នោះបានបង្កើតហើយនៅក្នុងតំបន់រំដោះនោះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា អ្នកដែលនៅតំបន់រំដោះនោះ ដែលចង់បន្តប្រើលុយទៀតនោះ តើពួកគាត់មានសេរីភាពក្នុងការចេញទៅនៅកន្លែងផ្សេងទៀតបានដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន បើនៅក្នុងសហករណ៍ហើយ អត់មានសេរីភាពចេញទៅនៅឯណាទៀតទេ ត្រូវធ្វើការក្នុងសហករណ៍។ ឯលុយ គេអាចទិញដូរជាមួយថៃបាន បើនៅជិតព្រំដែនថៃ។

**ស៖** បាទ សូមអរគុណ។ លោក នួន ជា ខ្ញុំចង់លើកសម្រង់នៃសេចក្តីថ្លែការណ៍របស់លោកមួយទៀត គឺសេចក្តីថ្លែងការណ៍នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ដដែល។ ខ្ញុំសូមយោងទៅទំព័រដែលលេខ ERN ជាភាសាខ្មែរគឺ 00755363 ដែលនៅកន្លែងនោះគឺថា លោកបានទាញការសន្និដ្ឋាននៃការប្រជុំនៃថ្ងៃទី-- ខែឧសភា ឆ្នាំ១៩៧៤ ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ។ លោកបានបញ្ជាក់ថា បញ្ហាទាំងអស់ របៀបវារៈនៅថ្ងៃនោះ គឺថាត្រូវបានពន្យល់ទាំងអស់ លោកបានលើកឡើងថាជាពិសេសត្រូវតែពង្រឹងសាមគ្គីភាពរវាងប្រជាជនមូលដ្ឋាន ហើយនិងប្រជាជនថ្មី ហើយនិងបង្រៀនឲ្យគាត់កុំឲ្យរើសអើងថាជា ថាប្រជាជនចាស់ ឬក៏ប្រជាជនថ្មី។ តើពិត បាទ តើលោកអាចបំភ្លឺពាក្យពេចន៍ទាំងអស់នេះបានទេ ថាប្រាប់យើងឲ្យច្បាស់ថាតើអ្នកណាដែលលោកចាត់ទុកថា ជាប្រជាជនមូលដ្ឋានហើយនិងអ្នកណាជាប្រជាជនថ្មី?

[១០:០៨:០០]

**ឆ៖** សូមគោរពលោកប្រធាន ប្រជាជនថ្មី គឺប្រជាជនដែលទើបជម្លៀសទៅ ឯប្រជាជនមូលដ្ឋាន គឺប្រជាជនដែលគេនៅចាស់ហើយ។ ដូច្នោះខាងគណៈអចិន្ត្រៃយ៍បក្ស ឬតាំងពីភូមិឃុំអីទៅអប់រំប្រជាជនថា កុំឲ្យមានការប្រកែប្រកាន់អី យើងខ្មែរទាំងអស់គ្នា មានអីៗចែកគ្នាហូបទៅ ហើយកុំប្រកែប្រកាន់ថាចាស់ ថាថ្មី អ្នកដែល-- ប៉ុន្តែពួកខូចហ្នឹងក៏វាមានដែរ វាចាក់វារុក ថានេះពួកថ្មី នេះ

ពួកចាស់។ ដូច្នោះ បញ្ហាវាបែកបាក់សាមគ្គីក៏មាន បញ្ហានេ៎! គេអ្នកល្អ គេយល់ក៏មាន វាស្មុគស្មាញណាស់។

**ស៖** តើយើងត្រូវយល់ថា នេះគឺជាការកំណត់ចំណាត់ថ្នាក់ ការបែងចែកធ្វើដោយបក្សកុម្មុយនីស្តកម្ពុជា ឬក៏ដោយគណៈមជ្ឈិមដែរឬទេ?

**ឆ៖** បញ្ហានេះ-- គោរពលោកប្រធាន ការពន្យល់ គឺមិនមានការបែងចែកទេ ឲ្យតែគេយល់ទៅ គេធ្វើខ្លួនគេហើយ ប្រជាជនចាស់ក៏ដោយ ប្រជាជនថ្មីក៏ដោយ មានអីជួយគ្នាទៅ ព្រោះសុទ្ធតែខ្មែរដូចគ្នា។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក នួន ជា៖**

ទៅបន្ទប់ទឹក។

**ប្រធានអង្គជំនុំ៖**

ទៅបន្ទប់ទឹក?

**លោក នួន ជា៖**

បាទ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងគឺពេលវេលាក៏សមល្មមនឹងសម្រាកដែរ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់កន្លះ។ សូមអញ្ជើញចូលវិញដើម្បី (ឮមិនច្បាស់)។

ឮទេ?

*(មីក្រូហ្វូនមិនដំណើរការ)*

[១០:១២:៥៦]

**អ្នកបកប្រែ៖**

អាឡូ! លោកប្រធាន ពីអ្នកបកប្រែឥឡូវនេះស្តាប់បានវិញហើយទាន។

**ប្រធានអង្គជំនុំ៖**

អាឡូ! ស្តាប់បានទេៗ?

**អ្នកបកប្រែ៖**

បាទ ស្តាប់បានហើយពីអ្នកបកប្រែ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

*អូខេៗ*។

បាទឥឡូវពេលនេះ សមល្មមនឹងសម្រាកហើយដែរ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅរហូដល់ម៉ោងដប់កន្លះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន ដោយសារបញ្ហាមូលហេតុសុខភាព និងបញ្ហាឈឺចង្កេះ លោក អៀង សារី ស្នើសុំលោកប្រធានមេត្តាអនុញ្ញាតឲ្យលោកចូលរួមសវនាការនៅបន្ទប់ខាងក្រោមសម្រាប់ថ្ងៃនេះ គឺគាត់សុំលះបង់សិទ្ធិចូលរួមផ្ទាល់។ អ៊ីចឹងសូមលោកប្រធានមេត្តាអនុញ្ញាតតាមសំណើ។ សូមអរគុណ។

[១០:១៣:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់នូវសំណើសុំរបស់លោក អៀង សារី តាមរយៈមេធាវីរបស់គាត់ស្នើសុំលះបង់សិទ្ធិមិនចូលរួមកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយដកខ្លួនថយទៅបន្តការតាមដានស្តាប់កិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ នៅបន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់មេ-- របស់លោក អៀង សារី ដែលស្នើសុំតាមរយៈមេធាវីរបស់គាត់ លះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងសវនាការ ហើយទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅខាងក្រោមបន្ទប់សវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍។ តម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិក្នុងការចូលសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សំឡេង រូបភាពសម្រាប់ជនជាប់ចោទតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលធ្វើសវនាការ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ទៅកាន់បន្ទប់ខាងក្រោម។ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា មកកាន់ឈើរាងវង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះ!

*(ជនជាប់ចោទ នួន ជា ទៅកាន់ឈើរាងវង់ក្រចកសេះ)*

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងសំណួរដែលលោកប្រធានបានសួរកាលពីដើម ខ្ញុំបានធ្វើការពិភាក្សាជាមួយនឹងខាងការិយាល័យរបស់ខ្ញុំរួចហើយ ដូច្នេះហើយយើងត្រូវការសឹងតែពេញមួយថ្ងៃតែម្តង។ ដូច្នេះហើយយើងអាចផ្តល់ជូនខាងដើមបណ្តឹងរដ្ឋប្បវេណីទុកឲ្យគាត់កន្លះម៉ោងបាន ក៏ប៉ុន្តែគឺវាពិបាកណាស់ ប្រសិនបើអង្គជំនុំជម្រះអាចផ្តល់ពេលវេលាដល់ដើមបណ្តឹងរដ្ឋប្បវេណីច្រើនជាងកន្លះម៉ោងនោះ។ សូមអរគុណច្រើន។

[១០:៣៥:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៦:១០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន យើងខ្ញុំបានពិភាក្សាជាមួយនឹងដៃគូរបស់ខ្ញុំ ហើយក៏បានពិភាក្សាជាមួយខាងតំណាងសហព្រះរាជអាជ្ញាដែរ ប៉ុន្តែខាងមេធាវីនាំមុខនៅតែបានជម្រាបលោកប្រធានមុន

នេះថា ចង់បានពេលពីរម៉ោង ប៉ុន្តែមានលទ្ធភាពអាចបន្ថយមកត្រឹមតែមួយម៉ោងកន្លះ។ តែបើសិនថាមានការលំបាកច្រើនសម្រាប់អង្គជំនុំជម្រះនៅក្នុងការចាត់ចែងម៉ោងនេះ គឺអាចបន្ថយមកត្រឹមមួយម៉ោងបាន ប្រសិនបើថាលោកប្រធានអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រមអនុញ្ញាតឲ្យមួយម៉ោង ហើយដូច្នេះខាងសហព្រះរាជអាជ្ញាកាត់បន្ថយពេលវេលាបន្តិចទៀតសម្រាប់ទៅ ផ្តល់កន្លះម៉ោងបន្ថែមទៅខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ជាកិច្ចបន្តអង្គជំនុំជម្រះ សូមផ្តល់វេទិកាទៅក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតំណាងបន្តតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

[១០:៣៧:៥៥]

**លោក បាណាបេ ណេគ្រី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោក នួន ជា មុននឹងពេលជិតសម្រាកអម្បាញ់មិញនេះ លោកបានពន្យល់ពីភាពខុសគ្នារវាងប្រជាជនមូលដ្ឋាន ហើយនិងប្រជាជនថ្មី។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ? ជាពាក្យពេចន៍ដែលលោកបានប្រើអម្បាញ់មិញដែរឬទេ?

**លោក នួន ជា៖**

**ឆ៖** លោកសួរថា-- គោរពលោកប្រធាន លោកសួរថាម៉េច?

**ស៖** បាទ លោក នួន ជា ខ្ញុំគ្រាន់តែចង់សង្ខេប ចង់ដឹងថាតើការសង្ខេបរបស់ខ្ញុំអម្បាញ់មិញនេះជាការត្រឹមត្រូវដែរឬទេ ទាក់ទងនឹងប្រជាជនចាស់ និងប្រជាជនថ្មី? លោកបានធ្វើការពន្យល់ទាក់ទងនឹងប្រធានបទនេះ។ តើមុនពេលយើងសម្រាកអំមិញនេះ លោកបានលើកឡើងអំពីបញ្ហានេះដែរឬទេ?

[១០:៣៩:១៩]

**ឆ៖** គោរពលោកប្រធាន លើកបញ្ហាអី? ខ្ញុំភ្លេចទៅហើយ។

**ស៖** លោក នួន ជា ដើម្បីកុំឲ្យមានបញ្ហាច្រើនទាក់ទងនឹងការពន្យល់របស់លោកនោះ ខ្ញុំគ្រាន់តែចង់រំឭកឡើងវិញអំពីភាពខុសគ្នាដែលលោកបានធ្វើការបែងចែកអម្បាញ់មិញរវាងប្រជាជនចាស់

ហើយនិងប្រជាជនថ្មី។ ខ្ញុំបានអានសេចក្តីប្រកាសរបស់លោកដែលបានលើកឡើងអំពីប្រភេទប្រជាជនទាំងពីរប្រភេទនេះ។ តើលោកអាចពន្យល់បានជាថ្មីម្តងទៀតបានទេ អំពីភាពខុសគ្នារវាងប្រជាជនចាស់និងប្រជាជនថ្មីនេះ?

**ធ៖** សូមគោរពលោកប្រធាន មិនមានភាពអីខុសគ្នាទេ មិនប្រកែប្រកាន់ទេ។ សំខាន់ន៏ ជួយគ្នាទៅវិញទៅមក។ អ្នកថ្មី គឺអ្នកដែលជម្លៀសមកនៅភូមិ មកនៅមូលដ្ឋាន។ ដូច្នោះ សាមគ្គីគ្នាទៅស្រឡាញ់គ្នាទៅ មានអីក៏ចែកគ្នាហូបទៅ។ ក៏ប៉ុន្តែវាចៀសផុត មិនផុតពីពួកខូចទេ គឺដូចខ្ញុំជម្រាបអ៊ីចឹងប៉ុន្តែភាគច្រើនគេល្អ។ ខ្ញុំជម្រាបអ៊ីចឹង អ្នកដែលគេត្រឹមត្រូវអីៗហ្នឹង អ្នកខ្លះដែលគេមានលុយមានអីខ្លះគេផ្ញើទៅទិញនៅថៃ នៅអីហ្នឹង ក៏គេមានហូបមានចុក យកមកចែកគ្នាហូបទៅ ស្រឡាញ់រាប់អានគ្នាទៅ ពីព្រោះថាជាតិខ្មែរដូចគ្នា ហើយស្រុកយើងវាសង្គ្រាមអ៊ីចឹង ត្រូវជួយគ្នាទៅ។ អានេះដែលតាមខ្ញុំចាំខ្ញុំនិយាយអ៊ីចឹង។

[១០:៤១:៥០]

**ស៖** អរគុណលោក នួន ជា។ អ៊ីចឹង តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើប្រជាជននៅឧដុង្គ ដែលត្រូវបានជម្លៀសនៅខែមីនា ឆ្នាំ១៩៧៤ ដើម្បីទៅនៅក្នុងសហករណ៍ពិសេសដែលនៅតំបន់និរតីនោះ។ តើប្រជាជននៅឧដុង្គនោះត្រូវបានចាត់ទុកថាជាប្រជាជនថ្មីដែរឬទេ?

**ធ៖** គាត់អ្នក-- គោរពលោកប្រធាន អ្នកទៅថ្មីក៏ចាត់ទុកជាអ្នក-- ដូចខ្ញុំជម្រាបអ៊ីចឹង គ្មានប្រជាជនចាស់ ប្រជាជនថ្មីអីទេ ប៉ុន្តែថាទៅនៅថ្មីទៅក៏គេហៅថា អ្នកមកថ្មីទៅ។ អ្នកមកថ្មីៗ នៅថ្មីទៅពីព្រោះឧដុង្គ ហើយនិងនៅជិតនោះ វានៅទៅមករកស៊ី ទាក់ទងគ្នាទៅមកវាស្គាល់ហើយ បងប្អូនគ្នាមិត្តភក្តិជាមួយគ្នានោះ។

[១០:៤៣:២០]

**ស៖** តើលោកអាចជម្រាបជូនយើងបានទេ អំពីលក្ខខណ្ឌដែលកំណត់ថា អ្នកនេះជាសមាសភាពល្អ កាលពីសម័យនោះ? តើលោកអាចបញ្ជាក់ប្រាប់បានទេ?

**ធ៖** គោរពលោកប្រធាន ខ្ញុំបញ្ជាក់បាន អ្នកល្អ គឺជាអ្នកដែលត្រឹមត្រូវ មានគុណធម៌ មានសីលធម៌ល្អ សាមគ្គីគ្នាល្អ ហើយគេមិនស៊ីមិនផឹក មិនពុករលួយ មិនពាលាអាវាសែ មិនកាចសាហាវ គឺថាអ្នកល្អហើយ។ ធម្មតាកសិករ គឺល្អទាំងអស់ បើតាមខ្ញុំគិតមើល ក្រៅពីបុគ្គលកសិករ បើនិយាយពីវណ្ណៈកសិករណ៎ា ល្អទាំងអស់។ ប៉ុន្តែបើនិយាយពីបុគ្គលកសិករ វាមានកសិករខ្លះទៅផឹកស៊ី ទៅស្រវឹង

ប្រឡៃប្រឡោ អាហ្នឹងក៏មាន ប៉ុន្តែមានតិចទេ។ អានេះបើនិយាយជាបុគ្គល។

[១០:៤៤:៣៩]

**ស៖** នៅក្នុងរយៈពេលនេះដដែល គឺថានៅមុនឆ្នាំ១៩៧៥ ការដែលប្រើពាក្យថា "កៀរប្រជាជន" នោះ។ តើជាពាក្យដែលបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់មែនទេនៅសម័យនោះ?

**ឆ៖** សូមគោរពលោកប្រធាន អត់ប្រើពាក្យ "កៀរ" ទេ ប្រើពាក្យ "ជម្លៀសបណ្ដោះអាសន្នសិន"។ ខ្លាចលោវាមានសង្គ្រាម។ ពីព្រោះវាច្របូកច្របល់ អាមេរិកក៏មាន ស្អីក៏មាន ហើយយួនក៏មានអីក៏មាន។ ហើយពួកទាហាន ពួក ពុត ឆាយ, ពួក ដាប ឈួន, ពួក ច័ន្ទ រង្សី, ពួក កៅ តក់, ពួក ហ៊ុល វង់ អានុភាព អីៗអស់នេះ។ វាសុទ្ធតែពួកចោរចាស់ណ៎ា។

**ស៖** បាទ សូមអរគុណ។ លោក នួន ជា ឥឡូវយើងត្រឡប់មកនិយាយ អំពីបុគ្គលម្នាក់ដែលខ្ញុំបានលើកឡើងថា ជាអ្នកទទួលខុសត្រូវជនជាតិវៀតណាម ហើយខ្ញុំអានឈ្មោះគាត់ខុសអំមិញ លោកបានកែខ្ញុំ។ អ៊ីចឹង ខ្ញុំសូមទោស បើសិនជាខ្ញុំអានខុសម្ដងនេះទៀត គឺថាលោក ង្វៀន វ៉ាន់ លិញ។ ខ្ញុំមិនដឹងនិយាយជាភាសាខ្មែរ អានយ៉ាងម៉េចឲ្យត្រូវនោះទេ។ សំណួរខ្ញុំគឺថា តើមានទំនាក់ទំនងអ្វីដែលលោករក្សាជាមួយលោក ង្វៀន វ៉ាន់ លិញ នោះ?

[១០:៤៦:៣២]

**ឆ៖** គោរពលោកប្រធាន គាត់ឈ្មោះ ង្វៀន វ៉ាន់ លិញ បើប្រៀបធៀបនឹងវៀតណាមឯទៀតគាត់ល្អដែរ។ ពិតមែនតែមាគ៌ានយោបាយវៀតណាមរួម មានមាគ៌ាវាត-- ឈ្លានពានវាតទីលេបទឹកដីបំបាត់ពូជសាសន៍។ ក៏ប៉ុន្តែ ង្វៀន វ៉ាន់ លិញ ជាបុគ្គលដែលអាចសន្ទនាជាមួយគ្នាបាន។ មានកិច្ចការអីគាត់មិនច្រឡោតតោតតូង ផាំ ហ៊ុង ទេ បើ ផាំ ហ៊ុង ផ្សេង អាហ្នឹងនិយាយខុសបន្តិចមុខក្រហម។ ធ្លាប់សួរខ្ញុំ ផាំ ហ៊ុង ហ្នឹងអ្នេ សួរខ្ញុំថា ការដែលវៀតណាមចរចាជាមួយអាមេរិកហ្នឹង មិត្តយល់ឃើញយ៉ាងម៉េច? ធ្លាប់សួរខ្ញុំអ៊ីចឹង។ ខ្ញុំយល់ឃើញ-- គាត់ថា ប្រជាជនខ្មែរយល់ឃើញយ៉ាងម៉េច? ខ្ញុំឆ្លើយថាប្រជាជនខ្មែរមិនរណបវៀតណាមទេ។ គាត់មុខឡើងក្រហម បើថាខ្ញុំគិតស្មានថា បើនៅដីគាត់ៗ ទះគុហើយ ប៉ុន្តែនេះគាត់នៅដីខ្ញុំ។ វាខុសគ្នាអ៊ីចឹង។ ង្វៀន វ៉ាន់ លិញ គាត់ឫកពាអីគាត់ល្អ ប៉ុនយោបាយវាតែមួយទេ។

[១០:៤៨:២២]

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា តាមរយៈលោក ង្វៀន វ៉ាន់ លិញ ហ្នឹង

ហើយ ដែលលោកធ្វើការទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាម។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន ត្រឹមត្រូវ។

**ស៖** អ៊ីចឹង លោកអាចដោះស្រាយតាមរយៈការចរចាគ្នាលើឧបទ្ទវហេតុ ដែលបានកើតឡើងរវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។ តើពិតដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ពិត បើចរចាជាមួយនឹង ង្វៀន វ៉ាន់ លិញ វាស្រួល។ ង្វៀន វ៉ាន់ លិញ គាត់ទទួលខុសដែរ គាត់ថា ខាងខ្ញុំ ខាងគាត់នោះក៏លំបាកដែរមិត្តអើយ ពួករត់ចោលជួរគេហៅថា ពួកនែ៎ រត់ចោលវៀតណាមដែលតស៊ូយូរទៅ វាធុញវា វារត់ចោលជួរ វាមកធ្វើអុកឡុកកន្លែងមិត្ត។ ដូច្នោះ បើមានការអីអធ្យាស្រ័យផងទៅ ហើយខ្ញុំក៏ប្រាប់ទៅវិញ។ ប្រាប់ថា ខាងខ្ញុំណោះក៏ខំអប់រំដែរ កុំប្រកែប្រកាន់អី។ ដូច្នោះនោះគឺថា ជាគូសន្ទនាជាមួយគ្នាបាន ក៏ប៉ុន្តែជ្រៅរបស់គេយ៉ាងម៉េចៗ ខ្ញុំមើលមិនធ្លុះដែរទេ។

[១០:៥០:២០]

**ស៖** លោក នួន ជា ខ្ញុំចង់ដកស្រង់សម្រង់មួយទៀត នៃសេចក្តីប្រកាសនៅថ្ងៃទី២២ វិច្ឆិកា ឆ្នាំ ២០១១ ដដែល ដែលនិយាយអំពី-- គឺសម្រង់ដែលមានលេខយោងជាភាសាខ្មែរ 00755348 នៅក្នុងសម្រង់នេះ លោកបានលើកឡើងថា នៅឆ្នាំ១៩៦៨ បក្សកុម្មុយនីស្តកម្ពុជាត្រូវបានបែងចែកជាពីរផ្នែក ដោយមានមូលដ្ឋាននៅរតនគិរី ដែលលេខគឺលោក ប៉ុល ពត ដែលគ្រប់គ្រងនៅភូមិភាគឦសាន ហើយមួយផ្នែកទៀតនៅភ្នំពេញដែលគ្រប់ដណ្តប់លើភូមិភាគពាយ័ព្យ និរតី បូព៌ា ឧត្តរ និងបក្សក្រុងភ្នំពេញ ដែលមានអនុលេខបក្ស នួន ជា ទទួលខុសត្រូវដឹកនាំ ហៅថា “ភូមិភាគកណ្តាល”។ សំណួរខ្ញុំដូចតទៅនេះ តើលោកអាចបញ្ជាក់បានទេ ទាក់ទងទៅនឹងកាតព្វកិច្ចក្នុងការដឹកនាំរបស់លោក នៅក្នុងផ្នែករបស់លោក ដែលថាលោកជាអ្នកទទួលបន្ទុកនៅក្រុងភ្នំពេញនោះ?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំមើលការខុសត្រូវរួមទេ ប៉ុន្តែខាងបច្ចេកទេស ខាងអីៗ ខាងខ្ញុំគ្មានកម្លាំងទេ។ ពីព្រោះខ្ញុំខាង-- កាលណោះ មានខាងសភា ឯមូលដ្ឋានគេ គេកម្លាំង គេមានអីៗ។ ដូច្នោះ ការទាក់ទងអីគ្នាល្អទេ មិនមានអីទេ។ មានការអីៗ មានគណៈកម្មការក្រុង ដែលមាន វន វ៉េត នោះ ជាលេខនោះ គេចាត់ចែង។

[១០:៥២:៥០]

**ស៖** បើ នួន ជា ខ្ញុំសូមកាត់ផ្តាច់របស់លោកបន្តិច ព្រោះថាខ្ញុំហាក់ដូចជាយល់ឃើញថា-- លោកអនុញ្ញាតឲ្យខ្ញុំនិយាយបានទេ ខ្ញុំសូមកាត់ផ្តាច់លោកបន្តិច ពីព្រោះថាលោកហាក់ដូចជាឆ្លើយមកក្នុងសំណួរខ្ញុំ នៅក្រោយរយៈឆ្នាំ៧៥ ទៅវិញ។ អ៊ីចឹង ខ្ញុំនិយាយអំពីឆ្នាំ១៩៦៨ គឺថាការងាររបស់លោក និងការងាររបស់លោក ប៉ុល ពត។ អ៊ីចឹង ខ្ញុំសូមរំឭកលោក អ៊ីចឹង សូមឲ្យលោកបញ្ជាក់អំពីការងារដឹកនាំ ភារកិច្ចដឹកនាំរបស់លោកនៅក្នុងផ្នែកដែលលោកជាអ្នកទទួលខុសត្រូវនោះ។ គឺថាមិន-- គឺថាចាប់ពីឆ្នាំ១៩៦៨?

[១០:៥៣:៣៧]

**ឆ៖** សូមគោរពលោកប្រធាន ចាប់ពីឆ្នាំ១៩៦៨ទៅ ក៏ខ្ញុំទទួលខាងការងារ ខាងអប់រំទេ ហើយ និងចុះ យូរៗចុះទៅមើលមូលដ្ឋានអំពីទំនប់ទឹក អំពីអីៗខ្លះ។ អាហ្នឹងឆ្នាំ១៩៦៨ ហើយប៉ុនសំខាន់ គឺអប់រំរៀនសូត្រ បើកវគ្គរៀនសូត្រ ព្រោះខ្ញុំទទួលខាងអប់រំ។

**ស៖** តើយើងត្រូវយល់ថា អ្នកទទួលខុសត្រូវតំបន់ពៀសាន និងនិរតី ហើយនិងតំបន់ឧត្តរនេះ មិននៅក្រោមការគ្រប់គ្រងរបស់លោកទេ នៅពេលនោះ ហើយនៅក្នុងខណៈដែលថាលោកជាលេខា-- ក្នុងខណៈលោកជាអ្នកទទួលខុសត្រូវនោះ?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំមិនមែនលេខាទេ អនុលេខា ទទួលខាងអប់រំ។ សូមបញ្ជាក់ម្តងទៀត។ លេខាគឺ ប៉ុល ពត នៅខាងពៀសាននោះទេ។

**ស៖** លោក នួន ជា អ្វីដែលលោកបាននិយាយនោះ គឺថា ប៉ុល ពត បានសម្រេចចិត្តគ្រប់គ្រងភូមិភាគពៀសាន ហើយលោកទទួលបន្ទុកខាងភូមិភាគផ្សេងទៀត។ តើយើងត្រូវយល់យ៉ាងដូច្នេះ ឬក៏យ៉ាងណា?

**ឆ៖** ពិតមែនដូចចែកជាពីរ ប៉ុន្តែទាក់ទងគ្នាតាមនីរសារ មាគ៌ាឯកភាពគ្នា ពីព្រោះឯកភាពគ្នាខាងមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធីហើយ មិនមានអីកែប្រែទេ។ ដូច្នោះគ្មានទំនាស់អីគ្នាទេ។

[១០:៥៧:០២]

**ស៖** ក៏ប៉ុន្តែដោយហេតុថានៅឆ្នាំ១៩៦៨នេះ វាស្របគ្នាទៅនឹងការចាប់ផ្តើមនៃការតស៊ូប្រដាប់អាវុធ ដែលបក្សកុម្មុយនីស្តកម្ពុជាបានជំរុញ។ តើយើងអាចទាញការសន្និដ្ឋានបានថា ការងារជាអ្នកគ្រប់គ្រងរបស់លោកនោះ គឺគ្រប់គ្រងយោធាផងដែរនៅក្នុងភូមិភាគដែលលោកកាន់កាប់នោះ?

**ឆ៖** សូមជម្រាបលោកប្រធាន គោរពលោកប្រធាន ខ្ញុំមិនបានគ្រប់គ្រងខាងយោធាទេ គឺភាគ

មួយៗគេគ្រប់គ្រង ដូចជាភាគបូព៌ា គេគ្រប់គ្រងខាងយោធាអីទៅ។ ឯខាងឧត្តរ អ៎ខាងនិរតី ខាងឧត្តរ ឯខ្ញុំគ្មានកម្លាំងយោធានៅនឹងដៃទេ មជ្ឈិមបក្សគ្មានកម្លាំងយោធាទេ។

**ស៖** លោក នួន ជា ខ្ញុំសូមលើកសម្រង់នៃសេចក្តីប្រកាសរបស់លោកមួយ ដែលនិយាយអំពីទស្សនកិច្ចរបស់សម្តេចនរោត្តម សីហនុ នៅឆ្នាំ១៩៧៣។ យោង លេខយោងជាភាសាខ្មែរគឺ00755355 អ៎53 សូមទោស។ លោកបានលើកឡើងនៅក្នុងវគ្គនេះ ទាក់ទងនឹងទស្សនកិច្ចនេះ លោក ប៉ុល ពត លេខាបក្សបានចាត់តាំងខ្ញុំ នួន ជា ដើម្បីរៀបចំផ្លូវ ទៅព្រះវិហារ ពីព្រះវិហាររហូតទៅអង្គរវត្ត។

សំណួរខ្ញុំដូចតទៅនេះ តើហេតុអ្វីបានលោកជាអ្នកថា ប៉ុល ពត ផ្តល់បេសកកម្មដែលយ៉ាងពិបាកយ៉ាងដូច្នេះ? ហេតុអ្វីបានជា ប៉ុល ពត ផ្តល់បេសកកម្មនេះទៅដល់លោក?

**ឆ៖** គោរពលោកប្រធាន ពីព្រោះជាភារកិច្ចសំខាន់ណាស់ កាលដែលទទួលព្រះកុរុណាយាងទៅ នែ៎ ទស្សនកិច្ចសៀមរាបនោះ។ ដូច្នោះ ខ្ញុំដែលទទួលខុសត្រូវខាងហ្នឹង ក៏ត្រូវទទួលភារកិច្ចរៀបចំពីព្រះវិហារ កន្លែងហ្នឹងគេហៅ កំពង់គ្រំ ហើយទៅដល់ប្រាសាទព្រះវិហារ។ ឯ ប៉ុល ពត ចាំទទួលព្រះកុរុណាដែលឡើងពីស្ទឹងត្រែងទៅដល់កំពង់គ្រំ ព្រះវិហារហ្នឹង។ ចែកដំណាក់គ្នាដែលប្រគល់ភារកិច្ចនេះឲ្យ ពីព្រោះរកអ្នក ទៅទុកចិត្តអ្នកឯទៀត ពីព្រោះបើមានគ្រោះថ្នាក់អីទៅបរាជ័យធំហើយ។

[១១:០១:00]

**ស៖** បាទសូមអរគុណលោក នួន ជា។ ដោយហេតុថា បេសកកម្មនេះត្រូវបញ្ចប់នៅក្នុងបរិបទសង្គ្រាម លោកអាចទទួលយកបានទេ គឺថាការទទួលខុសត្រូវនេះអាចធ្វើបាន-- មិនអាចធ្វើបានទេ បើសិនជាលោកពុំមានប្រព័ន្ធការពារនៅក្នុងភូមិភាគដែលទស្សនកិច្ចនោះ បានប្រព្រឹត្តឡើងនោះ។ តើយល់ព្រមដែរឬទេ ក្នុងការថាទាល់តែមានប្រព័ន្ធការពារបានអាចធ្វើទៅបាន?

**ឆ៖** គោរពលោកប្រធាន មានប្រព័ន្ធការពារ គឺខាងភូមិភាគគេការពារ ពង្រាយកងទ័ពទៅតាមផ្លូវទាំងអស់។ បើគ្មានកងទ័ពការពារធ្វើម៉េចទៅបាន។

**ស៖** ដូច្នេះ គឺជារឿងធម្មតាទេ នៅក្នុងការទាញការសន្និដ្ឋានថា លោកជាមនុស្សដែលជាគួរទុកចិត្តរបស់ ប៉ុល ពត។ លោកជាអ្នកទទួលខុសត្រូវជាមួយ ប៉ុល ពត ក្នុងការទទួលខុសត្រូវផ្នែកយោធានៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា។ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** គោរពលោកប្រធាន មិនត្រឹមត្រូវទេ ពីព្រោះខ្ញុំមិនទទួលខាងយោធាឯណា ប៉ុល ពត ទេ ជាប្រធានគណៈកម្មការយោធា។ ឯខ្ញុំទទួលខាងអប់រំ ហើយជានែ៎ ទទួលខាងអប់រំ។

[១១:០៣:១៦]

**ស៖** បាទ សូមអរគុណលោក នួន ជា។ ដើម្បីបញ្ចប់លើផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលជាកម្មវត្ថុនៃការពិភាក្សារបស់លោកនៅឆ្នាំ១៩៧៤។ ខ្ញុំសូមចោទសំណួរមួយទៅកាន់លោក តើលោកបានព្រាងទុកជាមុនថា លោកសង្ឃដែលនឹងត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញនោះត្រូវតែបញ្ជូនទៅសហករណ៍ ឬក៏នៅវត្តផ្សេងៗ តើមែនដែរឬទេ?

**ឆ៖** គោរពលោកប្រធាន គ្មានទេ។ គ្មានបញ្ជូនលោកសង្ឃឲ្យទៅនៅសហករណ៍ទេ។ លោកទៅនៅវត្តណាផ្សេងទៅ ទៅនៅវត្តតាមព្រៃ-- ទៅតាមព្រៃទៅ។

**ស៖** តើលោកបញ្ជាក់បានទេថា វត្តអារាម តើរាល់វត្តអារាមទាំងអស់នោះមានបើកទ្វារទេនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ?

[១១:០៤:៥២]

**ឆ៖** គោរពលោកប្រធាន បើគ្មានប្រជាជនទៅសហករណ៍អស់ហើយ មានតែអាចារ្យបីបួននាក់នៅថែរក្សាវត្ត មិនមែនទុកចោលឯណា។ មានអាចារ្យ មានអីៗថែរក្សាមើល រក្សាសម្អាត។

**ស៖** លោក នួន ជា សព្វថ្ងៃនេះគឺថាលោកអាយុ៨៦ឆ្នាំហើយ។ អ៊ីចឹង គឺថាលោកសុខភាពចុះខ្សោយហើយ យើងទាំងអស់គ្នាឃើញគ្រប់គ្នា ហើយខ្ញុំសូមកោតសរសើរនូវការប្រឹងប្រែងរបស់លោកក្នុងការឆ្លើយនឹងសំណួរទាំងអស់នេះ។ ក៏ប៉ុន្តែខ្ញុំចង់ចោទសំណួរទៀតទៅកាន់លោក ហើយសំណួរនេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ នៅខែឧសភា ឆ្នាំ១៩៧៤ លោកបានសម្រេចជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ តើពេលនោះលោកបានយល់ឃើញថា មនុស្សដែលអាយុចាស់ដូចលោកនេះ លើសពី៨០ឆ្នាំនោះជា ថាអាចចាត់ទុកជាថា ហានិភ័យ អាចជាភ្នាក់ងារ ជាអ្នកបង្កប់ខ្លួននៅទីក្រុងភ្នំពេញដែរឬទេ?

[១១:០៦:៤២]

**ឆ៖** គោរពលោកប្រធាន មិនដែលទេ មិនដែលគិតអ៊ីចឹងទេ ហើយគាត់ទៅក៏គាត់មិនមែនទៅធ្វើពលកម្មអីធំដុំទេ ទៅគ្រាន់តែជួយនេះជួយនោះធ្វើបន្តិធ្វើអីៗទៅបន្តិចបន្តួច។ មិនមែនទៅកាប់ដី កាប់ធ្លីអីដូចគេក្មេងៗទេ។

**លោក បាណបេ ណេគ្រី៖**

បាទ សូមអរគុណ ដែលបានឆ្លើយនឹងសំណួរ។ ខ្ញុំសូមបញ្ចប់ការសួរចម្លើយទៅកាន់លោក នួន ជា នៅពេលនេះ។ សូមអរគុណលោកប្រធាន។

[១១:០៧:៤០]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោក? មានសំណួរអីទៀតទេ។

សូមអញ្ជើញ!

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

សូមអរគុណលោកប្រធាន។ លោក នួន ជា ខ្ញុំសូមសួរសំណួរលោកពីរសំណួរបន្តទៀត។

**ស៖** ចាស ខ្ញុំចង់ជម្រាបសួរថា នៅលើកំណត់ហេតុដែលលោកសរសេរដៃ កាលពីព្រះរាជអាជ្ញាជម្រាបសួរលោកពីម្សិលមិញនេះ។ នៅលើចំណុចហ្នឹងថា ថ្ងៃ០១ មករា ឆ្នាំ៦៨ បក្សខាងភូមិភាគកណ្ដាលហ្នឹងបានប្រជុំសាខាភូមិភាគនៅក្នុងឆ្នាំ៦៨។ ហើយក្នុងឆ្នាំ៦៨ដែរ នៅក្នុងកំណត់ត្រារបស់លោក គឺមានការផ្ទុះអាវុធ។ ខ្ញុំចង់ជម្រាបសួរលោកថា ការប្រជុំភូមិភាគកណ្ដាល ពាក់ព័ន្ធអ្វីដែលនៅក្នុងការផ្ទុះអាវុធក្នុងឆ្នាំ៦៨ហ្នឹង?

[១១:០៨:៤៦]

**ឆ៖** ពាក់ព័ន្ធនឹងការបង្ក្រាបរាតត្បាតរបស់ពួករដ្ឋបាល លន់ នល់។ សូមគោរពលោកប្រធាន។ ឥឡូវឃើញថា បើថាមិនរួមផ្សំ មិនមែនតស៊ូអាវុធទទេ ខ្ញុំសូមបញ្ជាក់។ យកនយោបាយជាមូលដ្ឋាន អាវុធគ្រាន់តែការពារទេ បើគ្មានអាវុធការពារ ១កម្មាភិបាលមិនបានទេ។ ដូច្នោះកុំយល់ពាក្យពីរនេះខុសគ្នា។ ១) តស៊ូអាវុធ ២) តស៊ូអាវុធនយោបាយរួមផ្សំគ្នា។ យកនយោបាយជាមូលដ្ឋាន អាវុធបន្ទាប់បន្សំទេ។

**ស៖** ចាស ខ្ញុំសូមជម្រាបសួរលោកបន្តទៀតថា ហេតុអ្វីបានមានការផ្ទុះអាវុធហ្នឹង នៅក្នុងឆ្នាំ៦៨ហ្នឹង?

[១១:០៩:៤៤]

**ឆ៖** គោរពលោកប្រធាន ពីព្រោះមានការជិះជាន់សង្កត់សង្កិន ពីពួកវណ្ណៈ ពីកាន់អំណាចពីពួករដ្ឋបាលដូចជា គូ រុន, ពួកនែ លន់ នល់, សិរិមត: នេះ ហើយអ្នកណាទេទៀតប៉ុន្មាននាក់។

**ស៖** ចាស ហើយខ្ញុំចង់ជម្រាបសួរលោកបន្តថា តើការផ្ទុះអាវុធនោះផ្ទុះពីតំបន់ខាងណាមុនដែរលោក?

**ឆ៖** តាមខ្ញុំចាំផ្ទុះពីសំឡូតទៅវៃបាយតម្រាំ។

[១១:១០:២២]

**ស៖** ចាស សូមអរគុណ។ ខ្ញុំសូមសួរលោកមួយសំណួរ ដែលជាសំណួរចុងក្រោយ។ ខ្ញុំចង់ជម្រាបសួរលោកថា ក្នុងកិច្ចពិភាក្សារវាងលោក ជាមួយនឹងលោក ខឹម ងួន លោកបានលើកឡើងថា ទាំងវៀតណាម ទាំងចិន មិនយល់ស្របជាមួយនឹងការចាប់ផ្តើមផ្ទុះតស៊ូដោយអាវុធទេ ក្នុងឆ្នាំ៦៨។ ខ្ញុំចង់ជម្រាបសួរលោកថា ដោយហេតុ ទាំងចិន ទាំងវៀតណាមដែលមិនៗយល់ស្របឯកភាពនឹងការផ្ទុះអាវុធ ដែលលោកផ្ទុះអាវុធប្រឆាំងនឹងបក្សឯទៀតៗហ្នឹង ដូចជាការផ្ទុះអាវុធ ប្រឆាំងជាមួយសម្តេច សីហនុ ដែលយើងច្រើននិយាយថា ជាឪពុកខ្លួនឯងហ្នឹង។ អាហ្នឹងលោកៗយល់យ៉ាងម៉េចដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន មានតែវៀតណាមទេដែលប្រឆាំង ពីព្រោះវៀតណាមនេះពឹងលន់ នល់ ដើម្បីដឹកអាវុធពីកំពង់សោម កាត់តាមប្រទេសកម្ពុជាយកមកវ៉ៃនៅភាគខាងត្បូង។ ឯចិន បើតាមខ្ញុំចាំគេគ្មានមតិអីទេ គេថា រឿងហ្នឹងជារឿងផ្ទៃក្នុងរបស់ខ្មែរ។

**ស៖** ចាស ឥឡូវខ្ញុំចង់ជម្រាបសួរលោកថា តើវៀតណាមនិងចិនហ្នឹងមិនយល់ស្របជាមួយលោកនឹងការចាប់ផ្តើមតស៊ូអាវុធ ប្រឆាំងនឹងសម្តេច សីហនុ មែនទេ? លោកគ្រាន់តែឆ្លើយថា មែន ឬក៏មិនមែន។

[១១:១២:០៦]

**ឆ៖** វៀតណាមមិនយល់ស្របទេ ពីព្រោះពឹងរដ្ឋាភិបាលហ្នឹង។ ឯចិន គេគ្មានយោបល់អីទេ។

**ស៖** ចាស គ្មានយោបល់គឺគ្មានយោបល់ បានន័យថា គ្មានយោបល់ក្នុងការឯកភាពឲ្យលោកប្រឆាំងនឹងសម្តេចព្រះ សីហនុ មែនទេ?

**ឆ៖** ខ្ញុំមិនដឹងដែរ។

**ស៖** ចាសៗ។

**ឆ៖** មិនយល់ស្រប ក៏មិនយល់ស្រប មិនយល់ស្រប ក៏មិនយល់ស្រប។

**ស៖** ចាស សូមអរគុណ។ ខ្ញុំសូមជម្រាបសួរលោកមួយទៀតដែរថា លោកបានលើកឡើងផងដែរថា ង្វៀន វ៉ាន់ លិញ ហ្នឹង ប្រាប់លោកមិនឲ្យលោកតស៊ូអាវុធហើយ។ ហេតុអ្វីបានជាលោកនៅតែ ដូចថានៅតែប្រឆាំងនឹង ង្វៀន វ៉ាន់ លិញ ហ្នឹងទៀត ព្រោះថា លោកទទួលស្គាល់ថា ង្វៀន វ៉ាន់ លិញ ជាអ្នកមួយដែលថា មានអំណាចធំដែរនៅក្នុងវៀតណាមហ្នឹង?

[១១:១៣:០៨]

**ឆ៖** គោរពលោកប្រធាន ពីព្រោះបក្សកុម្មុយនីស្តកម្ពុជា មិនមែននៅក្រោមការដឹក-- ពេលនោះអត់នៅក្រោមការបង្គាប់បញ្ជារបស់វៀតណាមទេ។ ឯករាជ្យម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ឯវៀតណាមគេផ្សេង។ ម៉េចបានជាវៀតណាម មិនចង់ឲ្យខ្មែរតស៊ូអាវុធ ពីព្រោះខ្លាចដឹកអាវុធមកពីកំពង់សោមវាមិនបាន ហើយ ង្វៀន វ៉ាន់ លិញ ហៅខ្ញុំទៅជួប ស្នើខ្ញុំកុំឲ្យកាត់ផ្លូវ វាដឹកទៅវៀតណាមនោះ ដឹកទៅព្រំដែននោះ។ ខ្ញុំថាមិនអីទេ។

**ស៖** ហេតុអ្វីបានជាលោកកាត់ផ្លូវផ្តាច់ពីវៀតណាម ហើយនិងខ្មែរយើងហ្នឹង? ពេលនុ៎ង?

**ឆ៖** ជម្រាបលោកនែ៎ អត់មានកាត់ផ្លូវទេ។

**ស៖** ចុះលោកជម្រាបអង្គសវនាការអំមិញថា ង្វៀន វ៉ាន់ លិញ ហ្នឹងស្នើសុំឲ្យលោកកុំឲ្យមានការកាត់ផ្លូវ។ មែនទេអំមិញលោក?

**ឆ៖** បាទ គេស្នើមុន។

**ស៖** ដល់គេស្នើសុំលោកហើយ លោកក៏មិនមានកាត់ផ្លូវផ្តាច់ផ្លូវហ្នឹងទៅណ៎ាលោក។ មែនទេ?

**ឆ៖** អត់មានកាត់ទេ។

**ស៖** ចាស អ៊ីចឹងលោកធ្វើតាមសំណើរបស់ ង្វៀន វ៉ាន់ លិញ មែនទេលោក?

**ឆ៖** បាទ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអស់សំណួរលោកចៅក្រម។

[១១:១៤:២៩]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាកិច្ចបន្ត អង្គជម្រះសូមផ្តល់វេទិកា ទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពលោកចៅក្រមប្រធាន។ សូមគោរពលោក លោកស្រីចៅក្រមសមាជិក។ សូមគោរពអង្គសវនាការ។ សួរស្តីលោកអ្នកទាំងឡាយ នៅក្នុងបន្ទប់សវនាការ និងនៅក្រៅបន្ទប់សវនាការ។

សម្រាប់អង្គហេតុដែលបានសួរដេញដោលនេះ និងគិតមកត្រឹមពេលនេះ សហមេធាវីការពារក្តីលោក អៀង សារី ប្រកាន់ជំហរមិនសួរសំណួរទៅលោក នួន ជា ទេ។

សូមតុលាការមេត្តាជ្រាប។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ដែលបានបង្ហាញជំហរជាក់ច្បាស់ នៅចំពោះមុខអង្គជំនុំជម្រះក្នុងការរក្សាសិទ្ធិមិនតាំងសំណួរចំពោះ នួន ជា លើបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងអង្គហេតុនៅក្នុងកម្រិត ក្របខ័ណ្ឌបរិបទប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា។ សូមអញ្ជើញ!

[១១:១៥:៥៥]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល។ មេធាវីការពារលោក ខៀវ សំផន នៅពេលនេះ ពុំមានសំណួរដើម្បីដាក់តាំងជូនលោក នួន ជា នោះទេ សូមលោកចៅក្រមជ្រាប។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ហើយសុទ្ធតែបង្ហាញជំហរជាក់ច្បាស់ នៅចំពោះមុខអង្គជំនុំជម្រះ ហើយជាចុងក្រោយនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះកូនក្តីរបស់លោក នៅចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើមាន។

សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន យើងមានសំណួរមួយចំនួនដើម្បីសួរ ប៉ុន្តែខ្ញុំឃើញថា កូនក្តីរបស់ខ្ញុំដូចអស់កម្លាំងណាស់ ហើយខ្ញុំនឹងសួរទៅគាត់ នៅពេលដែលខ្ញុំទទួលចម្លើយរបស់គាត់ថា តើគាត់អាចតស៊ូបានឬអត់? ក្នុងការខ្ញុំដែលតាំងសំណួរនេះ ហើយនៅពេលក្រោយ ខ្ញុំនឹងសួរទៅគាត់។ អ៊ីចឹង ខ្ញុំចង់បានមតិពីកូនក្តីរបស់ខ្ញុំសិន ថាតើគាត់អាចនឹងឆ្លើយបានទេបន្តទៅទៀតនោះ?

[១១:១៧:៣២]

**ប្រធានអង្គជំនុំ៖**

លោក នួន ជា យ៉ាងម៉េចទៅ អាចបន្តឆ្លើយនឹងសំណួរដែលនឹងសួរដោយមេធាវីរបស់លោក នៅ

ក្នុងអំឡុងពេលពីនេះទៅ ដល់ពេលអាហារថ្ងៃត្រង់ទេ ប្រហែលជាសែសិបនាទីទេ?

**លោក នួន ជា៖**

ខ្ញុំអស់កម្លាំងណាស់ហើយ នេះខំទេ ដើម្បីនឹងឧបត្ថម្ភខាងតុលាការ។ បើនិយាយពីកម្លាំង ខ្ញុំគ្មានទេ។ សំខាន់ខួរក្បាលខ្ញុំ វាមិនទទួល។ ជួនណា ខ្ញុំឆ្លើយខុស ឆ្លើយត្រូវអីប៉ុណ្ណឹង។ ប៉ុនបើសំណួរបន្តិចបន្តួច ខ្ញុំអាចឆ្លើយបាន។ ខំៗ ខំរួមចំណែកដើម្បីស្វែងរកការពិត និងយុត្តិធម៌ជូនតុលាការ។

**ប្រធានអង្គជំនុំ៖**

សំណួរនេះ នឹងបន្តសួរលោក នួន ជា ដោយក្រុមមេធាវីការពារក្តីរបស់លោក នៅចំពោះមុខអង្គជំនុំជម្រះទេ មិនភាគីផ្សេងទៀតអស់សំណួរហើយ ចំពោះបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។ លោកអាចឆ្លើយបានទេ?

[១១:១៨:៥៨]

**លោក នួន ជា៖**

គោរពលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី។ គាត់បានបង្ហាញនូវជំហរក្នុងការព្យាយាមឆ្លើយតបទៅនឹងសំណួរដែលលោកនឹងសួរ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ម៉ៃខល ផេសមិន៖**

លោក នួន ជា ខ្ញុំនឹងសួរសំណួរទៅលោកមួយចំនួន ប៉ុន្តែប្រសិនបើៗ លោកយល់ថាអស់កម្លាំងពេក ឆ្លើយមិនកើត សូមលោកប្រាប់ខ្ញុំផង។

**ស៖** ខ្ញុំនឹងសួរសំណួរដំបូង។ សំណួរមួយចំនួនទាក់ទងទៅនឹង អំពីវ័យកុមារភាពរបស់លោកចាប់ពីឆ្នាំ គឺមុនពេលដែលលោកសម្រេចចិត្តទៅប្រទេសថៃ។ ហើយខ្ញុំក៏នឹងពិភាក្សាលើហេតុការណ៍មួយចំនួនដែរ ដែលជាកត្តាកំណត់ឲ្យលោកធ្វើការសម្រេចថាត្រូវចាកចេញ ឬត្រូវនៅ។ ជាពិសេសការជ្រើសរើសក្នុងការចូលបក្សកុម្មុយនីស្តនៅប្រទេសថៃ។ តើជាបឋម តើលោកអាចពន្យល់តុលាការបានទេ ថាតើស្ថានភាពនៅក្នុងភូមិដ្ឋាន នៅក្នុងផ្ទះរបស់លោកហ្នឹងដូចម្តេច? គឺស្ថានភាពមុនពេលដែលលោកចាកចេញទៅប្រទេសថៃ? សូមអញ្ជើញ!

[១១:២១:០៦]

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំសូមរៀបរាប់ដោយខ្លីៗ។ គ្រួសារខ្ញុំ ជាគ្រួសារ ម្ដាយខ្ញុំជារកស៊ីដេរ ឪពុកខ្ញុំទិញស្រូវអីលក់តិចតួច ហើយខាតទុន ខ្ចីលុយគេ ជំពាក់ប្រាក់គេ។ ពេលគេមកទារលុយម្ដងៗ ម្ដាយខ្ញុំយំស្រែកទៅ ហើយឪពុកខ្ញុំរត់ពួន។ ដូច្នោះ វាធ្វើឲ្យអារម្មណ៍ខ្ញុំហ្នឹង ដូចស្រងេះស្រងោចគ្រួសារច្រើនណាស់។ ដូច្នោះ គ្រួសារខ្ញុំវា-- ពីណាជំពាក់គេផង ឯណារកទទួលទានខាតផងអីផង។ ក៏ប៉ុន្តែចេះតែម្ដាយខ្ញុំ ចេះតែខំរកលុយឲ្យរៀនសូត្រ។ ដល់រៀនទៅ ដល់ឆ្នាំ១៩៤១ បារាំងប្រគល់បាត់ដំបងសៀមរាបអីឲ្យទៅថៃ ខ្ញុំក៏១៩៤១ហ្នឹង ខ្ញុំក៏ទៅរៀន ទៅថៃ ដើម្បីចង់ដឹង តើការគ្រប់គ្រងរបស់ថៃហ្នឹងវាយ៉ាងម៉េច? ក៏ប៉ុន្តែពេលដែលខ្ញុំ-- ម៉េចបានជាជំរុញឲ្យខ្ញុំទៅ? ពីព្រោះខ្ញុំឃើញនៅភូមិខ្ញុំ ភូមិខ្ញុំវាមានអ៊ីចេះ វាអ្នករាជការខ្មែរឈ្មោះ សហស្រីណាល់ ៗហ្នឹងត្រូវស្មៀនសាលាខេត្ត មានខ្ញុំបម្រើ កាលនោះមានរ៉ឺម៉ក។ ហើយអ្នករត់រ៉ឺម៉កហ្នឹង មិនដឹងធ្វើរ៉ឺម៉កខូចម៉េចទេ គាត់ក៏រត់។ កាលនោះសង្គមខ្មែរយើងដូចជានៅពាក់ទាសករនៅឡើយទេ។ ពាក់កណ្ដាលអាណានិគម ហើយនិងទាសករ។ ស្រីណាល់ ហ្នឹងឲ្យខ្ញុំបម្រើហ្នឹងទៅយកក្ដគោហ្នឹងមកវ៉ៃក្បាលគ្នាអ្នកដែលខ្ញុំបម្រើហ្នឹង គ្នាបត់ជើងសុំទោស ហើយសុំទោសទៀត ហើយនៅតែវ៉ៃ ហើយប្រជាជនទៅមើលលំបាក ឃើញវេទនាណាស់។ គ្នាសំពះដៃ ដៃអីសំពះសុំទោសអីច្រើនណាស់។ កាចណាស់ ស្រីណាល់ ហ្នឹង ធ្វើស្មៀនទេ។ អាហ្នឹងមួយទៅ។

[១១:២៤:០០]

ហើយមួយគ្រួសារហ្នឹង មានគ្រួសារមួយទៀតវ៉ៃគ្នាទៀត ហើយអ្នកដែលត្រូវវ៉ៃនេះឈ្មោះ គុជឯមីមួយទៀតនោះ គឺថាធ្វើន៎! គេហៅស្នាក្ដី ឈ្មោះលោក អ្នកឧញ៉ា នូ ភឹង ស្នាក្ដី។ ហ្នឹងក៏ឲ្យអ្នកបម្រើហ្នឹង វ៉ៃអ្នកបម្រើមួយទៀត ហើមមុខ ហើមមាត់អស់។ គ្នាមិនដឹងទៅណា រត់ទៅទៀតទៅ ហៅមកវ៉ៃទៀត។ ដូច្នោះ ខ្ញុំឃើញអីចឹងៗ ខ្ញុំដូចជាស្លុតចិត្តណាស់ ខ្មែរយើង។ ក៏ប៉ុន្តែមិនទាន់ចាប់អារម្មណ៍អីខ្លាំងក្លាទេ។ ប៉ុន្តែខ្ញុំចង់-- ដល់រួចទៅខ្ញុំដើរទៅវត្ត ដើរទៅវត្ត ឃើញគេដុតខ្មោច ឃើញគេដុតខ្មោច ក្រញ៉ង់ខ្ញុំនឹកថា ឱ!សង្វេគក្នុងខ្លួន សង្គមនេះតើ! ខ្ញុំទៅប្រាប់ម្ដាយខ្ញុំ ទៅប្រាប់ជីដូនខ្ញុំ ថា លោកយាយខ្ញុំចង់បួស។ លោកយាយថា អ្អែង ចង់បួសអីអ៊ំ្ហា នៅ-- បួសក៏បួសទៅ។ កាលនោះ ខ្ញុំបួសនេន បានប្រាំពីរថ្ងៃខ្ញុំឈប់ទៅ។ រួចទៅខ្ញុំកាលណោះ បារាំង កាលនោះថៃ បារាំង-- កាលនោះថៃប្រគល់បាត់ដំបងឲ្យបារាំងវិញហើយ ឲ្យមកខ្មែរវិញហើយ ខ្ញុំក៏ទៅរៀននៅស្រុកថៃទៅ។ ទៅរៀននៅស្រុកថៃខ្ញុំទៅនៅវត្ត ខ្ញុំទៅនៅវត្តហ្នឹងក៏លំបាកដែរ ព្រោះក្រ បានទៅនៅវត្តហ្នឹងក៏ឃើញការជិះជាន់ដែរ ខ្ញុំស្មានតែថៃ

ប្រជាធិបតេយ្យ ឃើញថៃជិះជាន់ បាញ់សម្លាប់ កាលធ្វើរដ្ឋប្រហារហ្នឹង បាញ់សម្លាប់រដ្ឋមន្ត្រីអស់បីបួននាក់។ អាហ្នឹងវាអ៊ីចឹង។ ដល់អ៊ីចឹង ទៅ គិត ខ្ញុំគិតថា ខ្ញុំកាលនោះរៀនច្បាប់ ហៅថាសាលារៀនធម្មាសាត្រ។ ខ្ញុំគិតថា រៀនៗដើម្បីអី? បម្រើអ្នកណា? បើថាសង្គមវាយ៉ាងនេះ នោះ។ ដូច្នោះ ខ្ញុំក៏ឈប់ទៅ។ ខ្ញុំឈប់រៀន។

[១១:២៦:៣៥]

ពេលនោះខ្ញុំធ្វើការដែរហើយ ខ្ញុំធ្វើការក្រសួងការបរទេសថៃ។ ខ្ញុំឃើញអ៊ីចឹង ខ្ញុំត្រឡប់មកស្រុកវិញ មកវិញខ្ញុំក៏ចូលតស៊ូ ដល់មកចូលតស៊ូនេះ ក៏ខ្ញុំធ្វើការងារខាងឃោសនាអប់រំ ហើយក្នុងពេលនុ៎ង ទាក់ទងខាងបូព៌ាៗហ្នឹង ន៎ែ ហេង សំរិនៗ ជាអ្នកនាំផ្លូវខ្ញុំពីភ្នំពេញ កាលនោះខ្ញុំទៅនៅភ្នំពេញទៅជួបវៀតណាម ទៅជួប ង្វៀន វ៉ាន់លិញ ហ្នឹង នៅដែនដីវៀតណាមនោះ។ ហេង សំរិន ហ្នឹងគាត់ក្រទេ រកតែក្របីឃ្វាលគ្មានផង មានតែខោខ្លីមួយហ្នឹង ក៏ប៉ុន្តែគាត់ល្អណាស់ គុណធម៌ សីលធម៌អីគាត់ ហើយតប៉ាន ក្លាហាន តស៊ូប្តូរផ្តាច់ ស៊ូលំបាកវេទនា។ នេះជីវិតរបស់គាត់វាអ៊ីចឹង។ ហើយដល់មកក្រោយមកទៀត ដល់នេះទៅគាត់បានធ្វើជាន៎ែ មេទ័ព ក្រោយរំដោះហ្នឹង។

[១១:២៨:០៣]

ដូច្នោះ គឺថា ជីវិតខ្ញុំហើយនិងលោក ហេង សំរិន ជាប់គ្នាណាស់ ខ្លាំងវាដេញអីៗរត់ទៅហើយគាត់ហ្នឹងរកស្រែគ្មានទេ រកស្រែធ្វើគ្មានទេ។ លំបាកវេទនាណាស់។ ហើយមួយទៀតហ្នឹង ជា ស៊ឹម ៗ គាត់ធ្លាប់រៀនជាមួយខ្ញុំដែរ។ ជា ស៊ឹម ហ្នឹងកាលហ្នឹងធ្វើគណៈស្រុកត្បូងឃ្មុំ គាត់ក៏ក្រដែរ អ្នកស្រែកណ្តាល ប៉ុន្តែ ពេលខ្លះក៏ខ្វះខាតទៅខ្ចីបុលគេទៅ។ ហើយមកក្រោយទៀត ខ្ញុំក៏មិនដឹងគាត់ធ្វើអីទេ ក្រោយរំដោះ។ ហើយតាំងពីនោះក៏មិនដែលបានជួបគ្នា។ នេះជាជីវិតៗខ្ញុំវាអ៊ីចឹង តស៊ូរហូតតាំងពីនោះមករហូតដល់ឥឡូវហ្នឹង។ ហើយការតស៊ូហ្នឹងគឺថា ដោយច្រើនណាស់ ទៅឈ្លោះ មិនត្រូវគ្នាជាមួយវៀតណាមទេ។ វៀតណាមហាមផ្តាច់កុំឲ្យបក្សកុម្មុយនីស្តកម្ពុជាហ្នឹងតស៊ូអាវុធ ពីព្រោះវាប៉ះពាល់ដល់ការទាក់ទងរវាងវៀតណាម ហើយនិងរាជរដ្ឋាបាលសង្គមរាស្ត្រនិយម។ ព្រោះកាលនោះ លន់ នល់ កំពុងដឹកអាវុធឲ្យ បើកាលណាតស៊ូទៅខ្លាចវាមានការប៉ះពាល់ ប៉ុន្តែខ្ញុំប្រាប់ថា ន៎ែ បក្សកុម្មុយនីស្តកម្ពុជា អត់រណបបក្សវៀតណាមទេ។ ផាំ ហ៊ុង មុខឡើងក្រហម។ ដូចខ្ញុំធ្លាប់និយាយមកហើយ។ ប៉ុន្តែខ្ញុំចេះតែតស៊ូទៅ ដល់តស៊ូទៅពេលរដ្ឋប្រហារ-- ដល់តស៊ូទៅ មុនវៀតណាមតស៊ូឆ្នាំ៦០ អាវុធគ្មាន អាមេរិកទម្លាក់គ្រាប់បែកខ្ទេចខ្ទីគ្មានកន្លែងនៅ រត់ទៅនៅកម្ពុជា ទាំង ឡេ យន់, ង្វៀន វ៉ាន់ លិញ

ទាំងគ្រួសារៗ រត់ទៅ ហើយប្រជាជនវៀតណាមនោះ តាមខ្ញុំដឹងគ្មានកន្លែងនៅទេ អស់ហើយ ចម្ការកៅស៊ូអីៗនេះស្លឹកឡើងក្រហមអស់ កប៉ាល់ហោះវាមើល កប៉ាល់ហោះB-52 ទម្លាក់។

[១១:៣០:៤០]

ដូច្នោះ វា-- វៀតណាម ហើយនិងខ្មែរហ្នឹងវាជាថាមិត្ត ថាសត្រូវក៏បាន។ អាមិត្ត ព្រោះគេវ៉ៃវៀត-- គេវ៉ៃអាមេរិកដែរ ប៉ុន្តែក៏វ៉ៃអីចឹង ក៏ប៉ុន្តែសត្រូវ ត្រង់ដែលវៀតណាមមានមហិតាណ្ហានពានវាតទីលេបទឹកដីកម្ពុជា។ ឯខ្មែរមានឧត្តមគតិឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនសម្រេចវាសនាខ្លួនដោយខ្លួនឯង។ ដូច្នោះប្រទេសទាំងពីរហ្នឹងជារូបភាពឃើញហាក់ដូចជាត្រូវគ្នា។ ក៏ប៉ុន្តែជាខ្លឹមសារពិតវៀតណាម គេចាំតែលេបយើងទេ។ ហើយបច្ចុប្បន្ននេះឃើញស្រាប់ហើយ ប៉ុន្មាន? ប៉ុន្មានៗ ខ្ញុំមិនដឹងទេ ព្រោះខ្ញុំមកនៅឯណេះទៅហើយ ខ្ញុំមកនៅមន្ទីរឃុំឃាំងហើយ។ ប៉ុន្តែចេះតែហៀរមកហើយ។ អាហ្នឹងគឺប្រវត្តិវាអីចឹង។ អានេះខ្ញុំសូមជម្រាបដោយខ្លីអីចឹង។

[១១:៣១:៥៧]

ដូច្នោះការតស៊ូហ្នឹងវាលំបាកវេទនា អីណាជាមួយអាមេរិកផង អាមេរិកវាទម្លាក់គ្រាប់បែកពីររយថ្ងៃពីររយយប់ អស់ប្រហែលពីរលានតោន តាមឯកសារបរទេសគេនិយាយទេ ខ្ញុំមិនដឹងទេ។ ឯវៀតណាមនោះ មានទាំងគ្រប់ វៀតណាម ហើយនិងអាមេរិក ដោយប្រៀបធៀបទៅ វៀតណាមឃោរឃៅជាងអាមេរិកទៀត ពីព្រោះគេវ៉ៃចូលដល់ចូលទៅចាត់តាំងរដ្ឋអំណាចអីក្នុងព្រៃ ក្នុងផ្ទៃរបស់ខ្មែរ។ ឯអាមេរិកគ្រាន់តែទម្លាក់គ្រាប់បែកទេ។ អាមេរិកអត់ចូលមកទេ វៀតណាមចូលមកទាំងមនុស្សតែម្តង រាប់ម៉ឺនរាប់សែន។ តាមខ្ញុំដឹងដូចជាកាលនោះមកនៅនេះពីរសែនប្រាំម៉ឺននាក់។

ដូច្នោះខ្មែរ កម្ពុជាប្រជាប្រជាធិបតេយ្យ ឯណាទប់ទល់អាមេរិកផង ឯណាទប់ទល់វៀតណាមផង ចេះយកខ្លួនរួចមកបានទៅប៉ុណ្ណឹង។ ហើយសព្វថ្ងៃនេះ លោកទាំងអស់គ្នាឃើញស្រាប់ហើយ ខ្ញុំនិយាយនេះ មិនមែនកុហកទេ និយាយការពិតតែម្តង ព្រោះតុលាការនេះត្រូវការការពិត យុត្តិធម៌ និងមានប្រយោជន៍សម្រាប់យុវជនជំនាន់ក្រោយ ឲ្យដឹង។ កុំឃើញថា អានេះគេហៅថា សព្វថ្ងៃនេះប្រៀបដូចជាពោះថ្លាន់រួតកូនទន្សាយអីចឹង។

សព្វថ្ងៃនេះ ខ្ញុំជម្រាបត្រង់ហើយចំពោះខ្លួនខ្ញុំគុកច្រវាក់អីមិនព្រួយទេ ប៉ុន្តែព្រួយអារឿងប្រទេសជាតិនេះ អនាគតវាយ៉ាងម៉េច សម្រាប់យុវជនជំនាន់ក្រោយនោះ។ តើ (ឮមិនច្បាស់)--

[១១:៣៣:៥៨]

**ប្រធានអង្គជំនុំ៖**

លោក នួន ជា អត្ថាធិប្បាយតបទៅនឹងសំណួរត្រឹមកម្រិតនៃបរិបទប្រវត្តិសាស្ត្រ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដូចមានចែងនៅក្នុងបណ្តាកថាខណ្ឌទាំងឡាយដែលមាននៅក្នុងដីកាដំណោះស្រាយពីខាងដើម។ គឺនិយាយកម្រិតត្រឹមតែបរិបទប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ។

សូមមេធាវីបន្តសំណួរផ្សេងទៀត!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោក នួន ជា គឺលោកអង្គជំនុំជម្រះបានកាត់សម្តីលោក ហើយត្រង់ចំណុចដែលលោកថាលោកមានការព្រួយបារម្ភទៅលើវាសនាប្រទេសជាតិនៅពេលខាងមុខ។ តើលោកចង់បានន័យយ៉ាងម៉េចសូមលោកជួយបញ្ជាក់?

**ឆ៖** គោរពលោកប្រធាន ខ្ញុំព្រួយបារម្ភចំពោះវាសនាប្រទេសជាតិទៅខាងមុខនោះ វាមិនដឹងទៅយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះជម្រាបហើយថា បញ្ហាក្រៅអង្គហេតុដែលកំណត់ឲ្យធ្វើសវនាការអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសួរ ហើយនិងឲ្យជនជាប់ចោទ និងអ្នកដែលត្រូវឆ្លើយនុំង ឆ្លើយក្រៅអង្គហេតុដែលអង្គជំនុំជម្រះកំណត់សម្រាប់ធ្វើសវនាការទេ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំគិតថា កូនក្តីរបស់ខ្ញុំអំមិញហ្នឹងបាននិយាយសម្តីបន្តិចបន្តួច ក៏ប៉ុន្តែមិនមានការបកប្រែនោះទេ ដូច្នេះហើយសូមឲ្យលោក នួន ជា ធ្វើការនិយាយសាជាថ្មីដើម្បីឲ្យមានការបកប្រែ ខ្ញុំស្តាប់ឮផង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យនិយាយក្រៅពីអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការទេ។ សូមមេធាវីពិនិត្យឡើងវិញអំពីអង្គហេតុបរិបទប្រវត្តិសាស្ត្រកម្ពុជា ដែលមានចែងនៅក្នុងដីកាដំណោះស្រាយដែលអង្គជំនុំជម្រះបានកំណត់ឲ្យធ្វើការដេញដោលនៅក្នុងកម្រិតសវនាការអង្គហេតុវគ្គមួយនៃសំណុំរឿង ០០២/០១។

[១១:៣៧:០៣]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំឃើញកូនក្តីរបស់ខ្ញុំអំមិញនេះ និយាយបន្តិចបន្តួច ដូច្នេះហើយខ្ញុំអត់ឮ ដូច្នេះទើបខ្ញុំសួរគាត់ថា គាត់ថា គាត់ចង់និយាយឡើងវិញដែរឬទេ? ដោយសារតែខ្ញុំអត់បានស្តាប់ឮដែរតាមការបកប្រែ។ ខ្ញុំអត់បានទទួលចម្លើយពីកូនក្តីរបស់ខ្ញុំ ទើបខ្ញុំសួរឲ្យបញ្ជាក់។ ដូច្នេះលោក នួន ជា លោកនិយាយសម្តីចុងក្រោយអម្បាញ់មិញនេះ តើលោកនិយាយអ្វីដែរ សូមលោកនិយាយសាជាថ្មីដើម្បីឲ្យមានការបកប្រែ ខ្ញុំស្តាប់ឮ បន្ទាប់មកខ្ញុំនឹងសួរសំណួរបន្ត? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

មេធាវី ខៀវ សំផន!

[១១:៣៧:៣៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន! ដោយអំមិញលោកមេធាវី មៃខល ផេសមិន គាត់ចង់ស្តាប់ពីសម្តីលោក នួន ជា ហើយខ្ញុំនៅជិតនេះ ខ្ញុំបានឮដោយសារសំឡេងមេក្រូអត់បានបើកទេ។ ប៉ុន្តែដោយសារសំឡេងវាកៀក ហើយខ្ញុំបានឮគាត់ នួន ជា មានប្រសាសន៍ថាគាត់ហ្នឹងអត់កម្លាំងហើយទៅលែងរួចហើយ។ អ៊ីចឹង ហើយប៉ុន្តែលោក នួន ជា គាត់អត់បានឆ្លើយនឹងសំណួរនេះថាសាជាថ្មី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅ នួន ជា?

**លោក នួន ជា៖**

សូមអនុញ្ញាតលោកប្រធាន សម្រាក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនដោយលោកបានបង្ហាញនូវស្ថានភាពជាក់ច្បាស់នៅចំពោះមុខអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះក៏បានយល់ដែរ មេធាវីអង្គុយចុះ! អំពីស្ថានភាពបញ្ហាសុខភាពរបស់លោក។ ដូច្នេះលោកមេធាវីអាចអង្គុយចុះបាន។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ សមល្មមនឹងសម្រាកហើយដែរ ដោយយើងមិនអាច

បន្តកិច្ចដំណើរការសវនាការតាមកាលបរិច្ឆេទដែលបានកំណត់រហូតដល់ម៉ោងដប់ពីរថ្ងៃត្រង់នោះ បានទេ ដោយមូលហេតុជនជាប់ចោទមានវ័យចាស់ ហើយអាចបង្ហាញពីភាពហត់នឿយដោយបញ្ហាសុខភាពនៃភាពចាស់ វ័យចាស់របស់ខ្លួន។ ដូច្នេះកិច្ចដំណើរការសវនាការសម្រាប់ព្រឹកនេះ អង្គជំនុំជម្រះសម្រេចបញ្ចប់។ ផ្អាកកិច្ចដំណើរការសវនាការត្រឹមនេះ ហើយដោយសាររសៀលនេះតាមផែនការនៃការវិភាគបានកំណត់គឺ យើងមានផែនការក្នុងការស្ដាប់សក្ខីកម្មសាក្សី ប្រាក់ យុត ប៉ុន្តែដោយកាលពីម្សិលមិញមេធាវីការពារក្ដីបានលះបង់នៅក្នុងការសួរចម្លើយចំពោះសាក្សីរូបនោះ។ ដូច្នេះ ពេលវេលាដែលគ្រោងសម្រាប់រសៀលនេះមិនអាចដំណើរការបានទេ ពីព្រោះផែនការបានជាចប់មុនតាមការគ្រោងទុក។

ហើយដូច្នេះ ភាគីជ្រាបថា នៅរសៀលនេះអង្គជំនុំជម្រះមិនធ្វើសវនាការទេ។ ហើយសវនាការនឹងលើកបន្តទៅថ្ងៃស្អែកចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ដូច្នេះសូមភាគី និងសាធារណជនជ្រាប។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយបង្គាប់ឲ្យនាំខ្លួនគាត់មកកាន់ទីនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំណត់។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១១:៤០ នាទី)*